**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការត្រៀមខ្លួនរបស់យុវជនកម្ពុជាក្នុង សមាហរណកម្មអាស៊ាន

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **លឹម ម៉ីលី**

សាស្ត្រាចារ្យណែនាំ

លោក **បណ្ឌិត ឈុន ណារ៉ែត**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី០៨

ឆ្នាំចូលរៀន ២០១១

ឆ្នាំសរសេរសារណា ២០១៥

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **លឹម ម៉ីលី** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រឆ្នាំទីបួន ជំនាន់ទី៨ ឯកទេស រដ្ឋបាលសាធារណៈ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមសំដែងនូវ កតញ្ញូតាធម៌ និងការគោរពដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ៖

លោកឪពុក អ្នកម្តាយដ៏មានគុណទាំងពីរដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងដល់នាងខ្ញុំតាំងពីចាប់កំណើតរហូតដល់ធំដឹងក្តី។ លោកទាំងពីរ តែងតែខិតខំយកចិត្តទុកដាក់ ពុះពារគ្រប់ឧបសគ្គ ដើម្បីផ្គត់ផ្គង់ឲ្យកូនៗបានទទួលការអប់រំតាំងពីថ្នាក់បឋម ដល់ថ្នាក់បរិញ្ញាប័ត្រ។ ពួកគាត់បានលះបង់កម្លាំងកាយចិត្ត ក្នុងការទូន្មានប្រៀនប្រដៅ និងចំណាយទ្រព្យសម្បត្តិដើម្បីឲ្យកូនៗ ទទួលបាននូវអនាគតល្អដោយមិនមានការរារែក។ បើគ្មានអ្នកមានគុណទាំងពីរ នាងខ្ញុំក៏មិនអាចទទួលបានអ្វីៗមកដល់សព្វថ្ងៃដែរ ព្រហ្មវិហារធម៌ និងឧបការគុណរបស់អ្នកមានគុណទាំងពីរ ពិតមានតំលៃមិនអាចកាត់ថ្លៃបាន។

ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ទាំងអស់នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

លោក លោកស្រីជាសាស្រ្តាចារ្យ នៃភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀន និងអប់រំឲ្យនាងខ្ញុំ ក៏ដូចជានិស្សិតទាំងអស់ឲ្យមានចំណេះដឹង ដើម្បីចូលរួមចំណែកកសាងប្រទេសជាតិទៅថ្ងៃមុខ។ ជាពិសេសលោកបណ្ឌិត **ឈុន ណារ៉េត** ដែលបានបង្ហាត់បង្រៀន ព្រមទាំងណែនាំនាងខ្ញុំក្នុងការសរសេរអត្ថបទស្រាវជ្រាវនេះ ដោយបានផ្តល់នូវគំនិត និងវិធីសាស្រ្តតាំងពីដើមរហូតបានសម្រេចជាលទ្ធផល។

ឯកឧត្តម **រស់ សាលីន** នាយកខុទ្ទកាល័យ និងជាអ្នកនាំពាក្យនៃក្រសួងអប់រំ យុវជន និងកីឡា និងលោក បណ្ឌិត **ភែម ឡី** អ្នកវិភាគ និងស្រាវជ្រាវសង្គម ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់បទសម្ភាសយ៉ាងក្បោះក្បាយ និងផ្តល់ឯកសារដ៏មានតម្លៃ ដែលជាចំណែកយ៉ាងសំខាន់ធ្វើឲ្យការស្រាវជ្រាវនេះអាចលេចជារូបរាងឡើង។

ជាចុងក្រោយ នាងខ្ញុំសូមបួងសួងឲ្យអ្នកមានគុណទាំងអស់ដែលបានរៀបរាប់ខាងលើទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីអាកខានឡើយ។

# អារម្ភកថា

កម្ពុជាបានចូលជាសមាជិកអាស៊ានកាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ និងធ្លាប់បានធ្វើជាប្រធានប្តូរវេនអាស៊ានពីរលើករួចហើយគឺនៅឆ្នាំ២០០២ និងឆ្នាំ២០១២។ វត្តមានរបស់កម្ពុជាទៅក្នុងសមាគមអាស៊ានពិតជាមានសារៈសំខាន់ណាស់ សម្រាប់សមាហរណកម្មប្រទេសនៅក្នុងតំបន់ក៏ដូចជា ទៅក្នុងពិភពលោកទាំងមូល បន្ទាប់ពីប្រទេសនេះបានងើបចេញពីភ្លក់ភ្លើងសង្គ្រាមវិនាសកម្ម និងពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ប្រទេសកម្ពុជា បានចាកចេញពីភាពឯកោរបស់ខ្លួន ហើយកំពុងធ្វើសមាហរណកម្ម និងបង្ហាញពីមុខមាត់ពីសមត្ថភាពរបស់ខ្លួនមិនត្រឹមតែនៅក្នុងតំបន់នោះទេ តែថែមទាំងលើឆាកអន្តរជាតិផងដែរ។

ដោយសារតែអាស៊ាន គ្រោងនឹងបង្កើតជាសហគមន៍អាស៊ាននៅឆ្នាំ២០១៥ ខាងមុខនេះ ហើយខណៈដែលកម្ពុជាធ្លាប់មានតួនាទីជាប្រធានអាស៊ានផ្លាស់វេនពីរដងរួចមក ហើយប្រជាជនកម្ពុជាភាគច្រើនបានស្គាល់កាន់តែច្បាស់ពីអាស៊ាន។ សហគមន៍អាស៊ានមាន សសរស្តម្ភធំៗចំនួន៣គឺ សហគមន៍នយោបាយ សេដ្ឋកិច្ច និងសង្គមវប្បធម៌។ ប្រាកដណាស់ សមាហរណកម្មសេដ្ឋកិច្ចអាស៊ានមានទាំងផលប្រយោជន៍ និងបញ្ហាប្រឈម ប៉ុន្តែអ្វីដែលសំខាន់នោះវានឹងអាចមានផលប៉ះពាល់ខ្លាំងដល់ប្រទេសកម្ពុជានោះគឺ លំហូរដោយសេរីនូវពលករជំនាញ ដែលជាកត្តាមួយជះឥទ្ធិពលខ្លាំងមកលើកម្លាំងពលកម្មកម្ពុជា ជាពិសេសនោះ គឺយុវជនកម្ពុជាផ្ទាល់តែម្តង។ ហេតុនេះ ទើបនាងខ្ញុំសំរេចចិត្តជ្រើសរើសយកប្រធានបទ **ការត្រៀមខ្លួនរបស់យុវជនកម្ពុជាក្នុងសមាហរណកម្មអាស៊ាន** ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំជាសារណាសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រនៅពេលនេះ។

នាងខ្ញុំសង្ឃឹមថា អត្ថបទដែលបានមកពីការស្រាវជ្រាវនាពេលនេះនឹងអាចចូលរួមក្នុងការចែករំលែកនូវចំណេះដឹងបន្ថែមទៀតទៅដល់ប្អូនៗនិស្សិតជំនាន់ក្រោយ និងអ្នកដែលមានបំណងចង់ស្វែងយល់ពីការត្រៀមខ្លួនរបស់យុវជនកម្ពុជាក្នុងសមាហរណកម្មអាស៊ាន បន្ថែមមួយកម្រិតទៀត។ ជាទីបញ្ចប់នេះ នាងខ្ញុំដឹងថាគ្មាននរណាម្នាក់ដែលធ្វើអ្វីមួយបានល្អឥតខ្ចោះនោះទេ ទោះចង់ ឬមិនចង់កំហុសដោយអចេតនារមែងតែងតែកើតមានដោយមិនអាចជៀសផុត។ បើសិនជាមានចំនុចខ្វះខាត ឬមានកំហុសកើតឡើងដោយប្រការណាមួយ ដោយនាងខ្ញុំមិនបានគិតទៅដល់នោះ នាងខ្ញុំសូមការខន្តីអភ័យទោសចំពោះកំហុសដោយអចេតនាទាំងនោះ ហើយនាងខ្ញុំរង់ចាំទទួលការរិះគន់ក្នុងន័យស្ថាបនាទាំងអស់នេះ ដើម្បីធ្វើជាប្រទីបនាំផ្លូវទៅរកភាពកាន់តែ សុក្រឹតនិងប្រសើរបន្ថែមទៀត។

# មាតិកា


បញ្ជីអក្សរកាត់ ..... iii

បញ្ជីឧបសម្ព័ន្ធ ..... iv


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ..... ០១

២. ចំណោទបញ្ហានៃការស្រាវ ..... ០២

៣. គោលបំណងនៃការស្រាវជ្រាវ ..... ០២

៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..... ០៣

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ..... ០៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ ..... ០៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ០៤


## ជំពូកទី១

## សញ្ញាណនៃអាស៊ាន


១.១. ការកកើតអាស៊ាន ..... ០៦

១.១.១. មូលហេតុ ..... ០៦

១.១.២. គោលបំណង ..... ០៧

១.១.៣. ការបង្កើតធម្មនុញ្ញអាស៊ាន ..... ០៩

១.២. តើអ្វីជាសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន? ..... ១០


## ជំពូកទី២

## គុណសម្បត្តិនៃសមាហរណកម្ម និងស្ថានភាពយុវជនកម្ពុជា


២.១. គុណសម្បត្តិ ..... ១២

២.១.១. ឱកាសការងារ ..... ១៣

២.១.២. ទំនាក់ទំនង និងវប្បធម៌ ..... ១៤

២.១.៣. បទពិសោធ និងបង្កើនចំណេះដឹង ..... ១៥

២.២. ស្ថានភាពយុវជន ..... ១៦

២.២.១. ស្ថានភាពយុវជនក្រោយសង្គ្រាម និងបច្ចុប្បន្ន........................................ ១៧
២.២.២. ការយល់ដឹងរបស់យុវជនកម្ពុជាអំពីទីផ្សារពលកម្មតាមរយៈការអង្កេត.. ១៩
២.២.២.១. សមត្ថភាពយុវជនកម្ពុជា ........................................................ ១៩
២.២.២.២. ចំណេះដឹងយុវជនទៅលើអាស៊ាន................................................ ២៧
២.២.២.៣. កម្រិតសមត្ថភាពយុវជនប្រកួតប្រជែងជាមួយយុវជនក្នុងតំបន់ .. ៣០

## ជំពូកទី៣

## បញ្ហាប្រឈម និងដំណោះស្រាយ

៣.១. បញ្ហាប្រឈម ........................................................................................ ៣២
៣.១.១. កង្វះការយល់ដឹងពីអាស៊ាន.............................................................. ៣២
៣.១.១.១. កង្វះការតាមដានព័ត៌មាន ............................................................ ៣២
៣.១.១.២. ការផ្សព្វផ្សាយនូវមានកម្រិត.......................................................... ៣៣
៣.១.១.៣. កង្វះឯកសារជាភាសាជាតិស្តីពីអាស៊ាន ........................................ ៣៣
៣.១.២. កង្វះធនធានមនុស្សដ៏ពូកែ ............................................................... ៣៣
៣.១.២.១. ប្រព័ន្ធអប់រំនៅទន់ខ្សោយ............................................................. ៣៤
៣.១.២.២. កង្វះអ្នកជំនាញវិជ្ជាជីវៈ .............................................................. ៣៤
៣.១.២.៣. បទពិសោធន៍មានកម្រិត ................................................................ ៣៥
៣.១.៣. កង្វះការត្រៀមខ្លួន ........................................................................... ៣៥
៣.១.៣.១. ជំនាញរឹង និងជំនាញទន់................................................................ ៣៥
៣.១.៣.២. កង្វះទំនុកចិត្តលើសមត្ថភាព និងការស្រាវជ្រាវ ............................ ៣៧
៣.១.៣.៣. ភាពភ័យខ្លាចកំណើននៃលំហូចូលកំលាំងពលកម្មជំនាញ................. ៣៧
៣.២. វិធានការដោះស្រាយ................................................................................ ៣៨
៣.២.១. រាជរដ្ឋាភិបាល ................................................................................... ៣៩
៣.២.២. ការត្រៀមខ្លួនរបស់យុវជន................................................................. ៤០
សេចក្តីសន្និដ្ឋាន.............................................................................................. ៤៣
អនុសាសន៍....................................................................................................... ៤៤
ឯកសារយោង ...................................................................................................
ឧបសម្ព័ន្ធ.........................................................................................................

# បញ្ជីអក្សរកាត់

- ASEAN : Association of South East Asian Nation
- AFTA : ASEAN Free Trade Agreement
- AEC : ASEAN Economics Community
- CLMV : Cambodia Laos Myanmar and Vietnam
- IAI : Initiative ASEAN Integration

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១៖ ធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

ឧបសម្ព័ន្ធទី ២៖ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន

ឧបសម្ព័ន្ធទី ៣៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា

ឧបសម្ព័ន្ធទី ៤៖ កម្រងសំណួរស្ទង់មតិយុវជនកម្ពុជា

ឧបសម្ព័ន្ធទី ៥៖ The ASEAN Declaration Bangkok (1967).

ឧបសម្ព័ន្ធទី ៦៖ សារព័ត៌មានសំខាន់ៗ

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ដោយសារសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ នឹងប្រែក្លាយខ្លួនឲ្យទៅជាសហគមន៍ នៅថ្ងៃអនាគត ដែលនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី១២នាខែមករាឆ្នាំ២០០៧ នេះបានសម្រេចបង្កើតសហគមន៍អាស៊ាន (ASEAN Economic Community) ហៅកាត់ថា AEC ក្នុងឆ្នាំ២០១៥ជំនួសឲ្យឆ្នាំ២០២០វិញ ដោយផ្អែកទៅលើការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (ASEAN Free Trade Agreement) ដែលហៅកាត់ថា AFTA សម្រាប់ធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់។ តំបន់ពាណិជ្ជកម្មសេរី ត្រូវបានបង្កើតឡើងផ្អែកទៅលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ដែលមានគោលដៅផ្លាស់ប្តូរប្រទេសជាសមាជិកមកនៅក្នុងតំបន់រួមមួយ ដែលមានលំហូរដោយសេរីនូវទំនិញ សេវាកម្ម ពលកម្ម ជំនាញនិង ការវិនិយោគ។

ការចូលទៅក្នុងតំបន់ពាណិជ្ជកម្មសេរីនេះ មានឧបសគ្គមួយចំនួនសម្រាប់ប្រទេសជាសមាជិក ដោយសារតែមានគំលាតសេដ្ឋកិច្ចរវាងប្រទេសជាសមាជិកថ្មី ដូចជា កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម (CLMV) និងប្រទេសអាស៊ានចាស់។ ដោយហេតុថា វិស័យឧស្សាហកម្មប្រទេសអាស៊ានចាស់មានលក្ខណៈល្អប្រសើរ បើប្រៀបធៀបនឹង ប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា នោះធ្វើឲ្យប្រទេសទាំងនេះអាចមានការលំបាកជាច្រើនស្របជាមួយនឹងគុណសម្បត្តិ ដែលពួកគេអាចនឹងទទួលបាននាប៉ុន្មានឆ្នាំទៅមុខទៀតនោះ។ នេះជាមូលហេតុ ដែលតម្រូវឲ្យមានការសិក្សាស្រាវជ្រាវបន្ថែមដើម្បីរកឲ្យឃើញថាតើមានគុណសម្បត្តិ ក៏ដូចជាកត្តាប្រឈមអ្វីខ្លះ និងវិធានការដោះស្រាយបែបណាខ្លះ ដែលកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍ និងជាប្រទេសអាស៊ានថ្មីអាចនឹងទទួលបាន នៅពេលឈានជើងចូលទៅក្នុងសហគមន៍សេដ្ឋកិច្ចជាមួយសមាជិកដ៏ទៃទៀត។

លំហូរសេរីនូវពលករជំនាញ ជាកត្តាចំបងមួយដែលនឹងប៉ះពាល់ដល់ជីវភាពប្រជាជនកម្ពុជាជាពិសេស អនាគតការងាររបស់យុវជនដែលតម្រូវឲ្យមានការស្វែងយល់ពីសមត្ថភាពយុវជនទាំងនោះថាតើពួកគេមានសមត្ថភាពជំនាញ ក៏ដូចជាខាងភាសាមានកម្រិតបែបណា ថាតើពួកគេយល់យ៉ាងណាដែរចំពោះគុណវុឌ្ឍិរបស់ខ្លួន និងចំណេះដឹងពាក់ព័ន្ធនឹងអាស៊ានដែលជាសហគមន៍ទៅថ្ងៃអនាគតរបស់ពួកគេ និងវិស័យសំខាន់ៗនៅកម្ពុជាដែលផ្សារភ្ជាប់ទៅនឹងសសរស្តម្ភដទៃទៀត។ ការស្វែងយល់ពីគុណវុឌ្ឍិរបស់យុវជនមានសារៈសំខាន់ណាស់ ក្នុងការរកវិធីដោះស្រាយនូវកត្តាប្រឈមទាំងឡាយដែលប៉ះពាល់ដល់អនាគតទីផ្សារការងាររបស់ពួកគេ។ ម៉្យាងទៀត ការយល់ដឹងរបស់ពួកគេទៅលើអាស៊ាន និងវិស័យសំខាន់ៗនៃប្រទេសនេះក៏ចាំបាច់ណាស់ដែរ ព្រោះថាបើពួកគេមិនបានដឹងឲ្យ

ច្បាស់ពីសក្តានុពលក្នុងស្រុក លក្ខខ័ណ្ឌ និងតម្រូវការនៃអនាគតទីផ្សារការងារ នោះនឹងធ្វើឲ្យពួកគេមានការពិបាកក្នុងការចាប់យកឱកាស ក៏ដូចជាប្រកួតប្រជែងជាមួយប្រជាជនដទៃទៀតក្នុងតំបន់ដែលនឹងមានតំបន់ការងាររួមគ្នា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទ៖ ការត្រៀមខ្លួនរបស់យុវជនកម្ពុជាក្នុងសមាហរណកម្មអាស៊ាន ជាចំណោទបញ្ហាចំបងដែលគ្របដណ្តប់ប្រធានបទនេះទាំងមូលគឺ *តើយុវជនកម្ពុជាមានការយល់ដឹងពីអាស៊ានកម្រិតណា ហើយពួកគេត្រូវត្រៀមខ្លួន ដូចម្តេចខ្លះចំពោះសមាហរណកម្មអាស៊ាន?*

### ចំណោទបញ្ហាបន្ទាប់បន្សំ

ក្នុងការសិក្សាទៅលើប្រធានបទនេះ ចំណោទបញ្ហាបន្ទាប់បន្សំមានដូចតទៅ ៖

១. តើអាស៊ានគឺជាអ្វី ហើយអ្វីជាសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន?

២. តើសមាហរណកម្មអាស៊ានផ្តល់គុណសម្បត្តិអ្វីខ្លះដល់យុវជនកម្ពុជា ហើយស្ថានភាពដែលទាក់ទងទៅនឹងយល់ដឹងពីអាស៊ានកម្រិតណា?

៣. តើយុវជនកម្ពុជាប្រឈមនឹងបញ្ហាបែបណាខ្លះ ហើយនឹងមានដំណោះស្រាយយ៉ាងណាសម្រាប់អនាគតការងាររបស់ពួកគេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

មូលហេតុដែលធ្វើឲ្យនាងខ្ញុំលើកយកប្រធានបទនេះមកសិក្សា គឺដោយសារការខិតជិតមកដល់របស់សហគមន៍សេដ្ឋកិច្ចអាស៊ានដែលប្រជាជនយើង ជាពិសេសយុវជនភាគច្រើន មិនសូវមានចាប់អារម្មណ៍ និងយកចិត្តទុកដាក់នៅឡើយទេ ហើយតាមរយៈអត្ថបទសិក្សាស្រាវជ្រាវនេះ នាងខ្ញុំមានគោលបំណងដើម្បីសិក្សាឲ្យស្គាល់ពីអាស៊ាន ក៏ដូចជា គុណសម្បត្តិនៃការចូលសមាហរណកម្មក្នុងតំបន់ និងការយល់ដឹងរបស់យុវជនកម្ពុជាទាក់ទងនឹងអាស៊ាន ព្រមទាំងបង្ហាញពីទិដ្ឋភាពតម្រូវការទីផ្សារការងារទៅថ្ងៃអនាគត ហើយដើម្បីសិក្សាពីគុណវុឌ្ឍិ និងកម្រិតសមត្ថភាពរបស់យុវជនកម្ពុជាក្នុងការប្រកួតប្រជែងជាមួយយុវជនក្នុងតំបន់ដទៃទៀត។ បន្ទាប់មក ធ្វើការសិក្សាកត្តាប្រឈមអ្វីខ្លះដែលជះឥទ្ធិពលដល់យុវជនកម្ពុជារួមទាំងវិធានការដោះស្រាយ។ ជាចុងក្រោយ គឺដើម្បីក្រើនរំលឹកស្មារតី និងផ្តល់នូវលទ្ធផលដែលបានសិក្សាដល់មិត្តអ្នកអាន ជាពិសេសយុវជនទូទៅឲ្យបានទទួលចំណេះដឹងទាក់ទងទៅនឹងប្រធានបទនេះ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

អត្ថបទនេះ នឹងធ្វើការសិក្សាខ្លះៗទៅលើការកកើតរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងការចូលជាសមាជិកអាស៊ានរបស់កម្ពុជា ដែលនាងខ្ញុំនឹងផ្តោតសំខាន់ទៅឥទ្ធិពលរបស់វាមកលើទីផ្សារការងារកម្ពុជា ហើយថាតើយុវជនគួរត្រៀមខ្លួនបែបណា។

ដូចនេះចំពោះប្រធានបទខាងលើ គឺទាក់ទងទៅនឹងចំណេះដឹង និងសមត្ថភាពរបស់យុវជនដែលជាហេតុនាំឱ្យការស្រាវជ្រាវធ្វើឡើងក្នុងទំហំចំពោះបុគ្គលដែលជាយុវជនតែប៉ុណ្ណោះ។ ម៉្យាងវិញទៀតក្នុងការសិក្សាទៅលើប្រធានបទនេះ តម្រូវឲ្យមានការចូលរួមឆ្លើយសំណួរដែលបានចងក្រងរួចពីសំណាក់មិត្តយុវជនមកពីប្រាំមហាវិទ្យាល័យខុសៗគ្នា ដើម្បីឲ្យពួកគេបង្ហាញពីកម្រិតសមត្ថភាពអប់រំ និងដើម្បីធ្វើតេស្តពួកគេខ្លះៗទៅលើចំណេះដឹងទូទៅពាក់ព័ន្ធនឹងអាស៊ាន។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះនាងខ្ញុំបានប្រើវិធីសាស្ត្រចំនួនពីរយ៉ាងគឺ៖

**ទិន្នន័យចម្បង៖** តាមរយៈទិន្នន័យចម្បងនេះ ត្រូវបានរៀបចំ និងបង្កើតឡើងក្រោមរូបភាពនៃការសាកសួរព័ត៌មានផ្ទាល់តាមរយៈការសម្ភាស នាយខុទ្ទកាល័យ នៃក្រសួងអប់រំយុវជន និងកីឡា និងអ្នកស្រាវជ្រាវខាងការអភិវឌ្ឍសង្គម។

**ទិន្នន័យបន្ទាប់បន្សំ៖** ចំណែកឯទិន្នន័យបន្ទាប់បន្សំនេះវិញ គឺត្រូវបានធ្វើតាមរយៈ ការប្រមូលឯកសារ សៀវភៅ និងទិន្នន័យដែលមានជាធរមាន ព្រមទាំងឯកសារដកស្រង់ចេញពីអ៊ីនធឺណិត ដូចជាគេហទំព័ររបស់អាស៊ាន កាសែត និងប្រមូលគំនិតយោបល់ពីនិស្សិតចំនួន ១៥០នាក់ពី៥សាកលវិទ្យាល័យ ដោយឲ្យពួកគេឆ្លើយសំណួរមួយចំនួនដែលបានចងក្រងរួច និងទទួលការពន្យល់ណែនាំពីសាស្ត្រាចារ្យណែនាំសារណាបញ្ចប់ការសិក្សា។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាលើប្រធានបទនេះបានផ្តល់សារៈប្រយោជន៍ពីការស្រាវជ្រាវដូចជា៖

- ❖ ធ្វើឲ្យនាងខ្ញុំសិក្សាយល់កាន់តែច្បាស់ពីអាស៊ាន ដែលជាអនាគតសហគមន៍របស់ប្រជាជនក្នុងតំបន់ទាំងអស់
- ❖ ធ្វើឲ្យនាងខ្ញុំដឹងពីប្រវត្តិ ការកកើត គោលបំណងនិងមូលហេតុនៃការបង្កើតអាស៊ាន
- ❖ ធ្វើឲ្យនាងខ្ញុំសិក្សាស្វែងយល់ពីគុណសម្បត្តិ និងការត្រៀមខ្លួនរបស់យុវជនកម្ពុជាចូលទៅក្នុងសមាគមន៍នេះ។

❖ ធ្វើឲ្យនាងខ្ញុំយល់ពីអ្វីទៅជាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងកត្តាជះឥទ្ធិពលផ្សេងៗមកលើកម្ពុជា ជាពិសេសទីផ្សារការងារនិងយុវជន។

❖ ធ្វើឲ្យនាងខ្ញុំអាចស្វាបស្ទង់ពីកម្រិតចំណេះដឹងអប់រំនិងជំនាញរបស់យុវជនខ្មែរ

❖ ធ្វើឲ្យនាងខ្ញុំអាចសិក្សាពីតម្រូវការទីផ្សារការងារនៅពេលមានសមាហរណកម្មក្នុងតំបន់

❖ ធ្វើឲ្យនាងខ្ញុំអាចស្វាបស្ទង់ពីកម្រិតសមត្ថភាពនិងគុណវុឌ្ឍិយុវជនមានសម្រាប់ការប្រកួតប្រជែងនៅក្នុងអនាគតទីផ្សារការងារ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឲ្យការស្រាវជ្រាវនេះទទួលបាននូវលទ្ធផលល្អ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់នោះគឺ ទាមទារឲ្យមានការកំណត់ជារចនាសម្ព័ន្ធជាក់លាក់មួយ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ។ សារណាស្រាវជ្រាវនេះចែកចេញជា បី ជំពូក។ ជំពូកទី១៖ សញ្ញាណនៃអាស៊ានដែលបង្ហាញពីមូលហេតុ ក៏ដូចជាគោលបំណងការកកើតអាស៊ាន ហើយថាតើអ្វីជាសមាហរណកម្មអាស៊ាន។ ចំណែកឯជំពូកទី២៖ គុណសម្បត្តិនៃសមាហរណកម្ម និងស្ថានភាពយុវជនកម្ពុជា ដែលបកស្រាយ និងបង្ហាញពីផលប្រយោជន៍ដែលយុវជនកម្ពុជាទទួលបាននៅពេលដែលសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននឹងចូលមកដល់នាពេលដ៏ខ្លីខាងមុខនេះ និងបង្ហាញពីស្ថានភាពយុវជនកម្ពុជាទាក់ទងទៅនឹងសមត្ថភាពជំនាញ និងការយល់ដឹងទៅលើអាស៊ានតាមរយៈការស្ទង់មតិ។ សម្រាប់ជំពូកទី៣៖ បញ្ហាប្រឈម និងដំណោះស្រាយ ដែលបកស្រាយពីគុណវិបត្តិអ្វីខ្លះ ដែលយុវជនកម្ពុជានឹងប្រឈមនៅពេលសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ហើយរាជរដ្ឋាភិបាល និងយុវជនមានវិធានការដោះស្រាយបញ្ហាទាំងនោះដោយរបៀបណា។

# ជំពូកទី១
# សញ្ញាណនៃអាស៊ាន

អាស៊ាន (ASEAN) ជាពាក្យកាត់ភាសាអង់គ្លេសដែលមកពីពាក្យថា"Association of South East Asian Nations" ប្រែជាភាសាខ្មែរថាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍បង្កើតឡើងនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧ នៅទីក្រុងបាងកក ប្រទេសថៃ ដែលរួមមានប្រទេសស្ថាបនិកចំនួន៥ប្រទេស គឺប្រទេសថៃ ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូណេស៊ី និងហ្វីលីពីន ក្រោយមកមានប្រទេសជាសមាជិកចំនួន៥ប្រទេសទៀត ចូលបន្តបន្ទាប់ ដែលក្នុងនោះរួមមានៈ ប្រទេសព្រុយនេ សមាជិកទី៦ ចូលនៅថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៨៤។ ប្រទេសវៀតណាម សមាជិកទី៧ ចូលថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ១៩៩៥។ ប្រទេសឡាវ និងប្រទេសភូមា ជាសមាជិកទី៨ និង៩ ចូលថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ១៩៩៧។ ចុងក្រោយ ប្រទេសកម្ពុជា សមាជិកទី១០ ចូលនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩។ ក្រៅពីនេះអាស៊ានក៏មានបាវចនាមួយដែលពោរពេញដោយអត្ថន័យគឺ ចក្ខុវិស័យមួយ អត្តសញ្ញាណមួយ សហគមន៍មួយ។[1] រីឯភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងអាស៊ានគឺភាសាអង់គ្លេស។[2] លើសពីនេះទៅទៀត អាស៊ានក៏មាននិមិត្តសញ្ញា និងអត្តសញ្ញាណផងដែរៈ អំពីអត្តសញ្ញាណអាស៊ានត្រូវលើកកម្ពស់អត្តសញ្ញាណរួមរបស់ខ្លួន និងក្នុងន័យរបស់ប្រជាជនដើម្បីធ្វើឲ្យសម្រេចនូវតម្លៃគោលដៅ និងជោគវាសនារួមគ្នារបស់អាស៊ាន។[3] អំពីទង់អាស៊ាន និងនិមិត្តសញ្ញាវិញគឺតំណាងឲ្យសហគមន៍អាស៊ានមួយដែលមានស្ថេរភាព សន្តិភាព រួបរួមគ្នា និងប្រកបដោយថាមពល។ រីឯពណ៌របស់និមិត្តសញ្ញា និងទង់អាស៊ានមានពណ៌ខៀវ ក្រហម ស និង ពណ៌លឿង ដែលពណ៌ទាំងអស់នេះតំណាងឲ្យពណ៌សំខាន់ៗ នៃទង់ជាតិរបស់ប្រទេសសមាជិកទាំងអស់។[4]

ចំណែកគួស្រូវទាំង១០ តំណាងឲ្យសុបិនរបស់បិតាបង្កើតអាស៊ានដែលមានបំណងប្រមូលផ្តុំប្រទេសទាំង១០នៅអាស៊ីអាគ្នេយ៍រួបរួមគ្នា ឲ្យក្លាយជាសហគមន៍មួយប្រកបដោយមិត្តភាព និងសាមគ្គីភាព។ ចំពោះសញ្ញារង្វង់ព័ទ្ធជុំវិញ គឺតំណាងឲ្យភាពឯភាពគ្នារបស់អាស៊ាន។[5]

---

[1] ធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍, ១៥ ធ្នូ ២០០៨,មាត្រា៣៦។

[2] ដដែល,មាត្រា៣៤។

[3] ដដែល, មាត្រា៣៥។

[4] ដដែល, ឧបសម្ព័ន្ធទី៣។

[5] ដដែល, ឧបសម្ព័ន្ធទី៤ ។

## ១.១. ការកកើតអាស៊ាន

អាស៊ានត្រូវបានបង្កើតឡើង ដើម្បីខ្ទប់ឥទ្ធិពលកុំមុយនីស្តហើយបើគេពិនិត្យមើលផែនទីតំបន់សម័យនោះ ឃើញថាប្រទេសស្ថាបនិកទាំងប្រាំ ដែលមានថៃ ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូណេស៊ី និង ហ្វីលីពីន បានបង្កើតជាខ្សែក្រវាត់មួយព័ទ្ធជុំវិញឥណ្ឌូចិនដែលជាជង្រុកនៃមនោគមវិជ្ជា និងបដិវត្តន៍កុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍។[6]

ក្រោយមកទៀត គឺចាប់ពីដើមទសវត្សទី៩០ទៅទើបអាស៊ានបានបោះជំហានចូលក្នុងសករាជថ្មី ពីព្រោះសង្គ្រាមត្រជាក់បានបញ្ចប់ ដោយបានផ្លាស់ប្តូរអស់រលីងនូវបរិបទភូមិសាស្ត្រនយោបាយនៃអាស៊ីអាគ្នេយ៍ និងបានធ្វើឱ្យបណ្តាប្រទេសទាំងអស់ក្នុងតំបន់លែងជាសត្រូវនឹងគ្នាទៀតហើយ។ ចាប់ពីពេលនោះមក អាស៊ានបានសម្រេចបើកទ្វារទទួលបណ្តាប្រទេសមួយចំនួនដែលនៅក្នុងអតីតកាលជាសត្រូវរបស់ខ្លួន។

### ១.១.១. មូលហេតុ

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី៨ខែសីហា ឆ្នាំ១៩៦៧ ដោយប្រទេសថៃ ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូណេស៊ី និង ហ្វីលីពីន មានគោលដៅពីរសំខាន់ៗកាលសម័យនោះ។

គោលដៅទីមួយគឺរំងាប់ភាពតានតឹងរវាងបណ្តាប្រទេសស្ថាបនិកទាំងប្រាំ។ដោយសារតែទំនាស់រវាងប្រទេសជាសមាជិក ជុំវិញជម្លោះដែនដី ការបែងចែកសហព័ន្ធ ដែលធ្វើឲ្យមានភាពរកាំរកូសនេះហើយបានជំរុញឲ្យប្រទេស ថៃ ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូណេស៊ី និងហ្វីលីពីន បង្កើតអាស៊ាន (ASEAN)ឡើងនៅឆ្នាំ១៩៦៧ ដើម្បីងាយស្រួលជជែកគ្នា និងដើម្បីជៀសវាងកុំឲ្យមានសង្គ្រាមផ្ទុះឡើង។ រីឯគោលដៅទីពីរនៃការបង្កើតអាស៊ានកាលសម័យនោះ គឺរួបរួមគ្នាទប់ទល់នឹងមនោគមវិជ្ជាកុម្មុយនីស្តដែលកំពុងវាយលុកចូលមកដល់អាស៊ីអាគ្នេយ៍តាមរយៈសង្គ្រាមនៅវៀតណាម។

ក្នុងទសវត្សឆ្នាំទី៦០ និន្នាការតំបន់និយម (Regionalism)បានកើតឡើងតាមរយៈកត្តាសំខាន់ពីរៈ (១) កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ក្នុងគោលបំណងបង្កើតរចនាសម្ព័ន្ធទីផ្សាររួម និងតំបន់ពាណិជ្ជកម្មសេរី (២) ការពារការវាយទីផ្នែកពាណិជ្ជកម្មរបស់មហាអំណាចសេដ្ឋកិច្ចធំៗ ជាពិសេសវត្តមានប្រទេសជប៉ុន និងចិននៅឥណ្ឌូចិន និងក្នុងតំបន់ទាំងមូល។ ដោយសារ ប្រការនេះហើយ ទើបចាប់ពីពេលនោះ

[6] ហោណាំហុង, "អាស៊ាន និងសមាហរណកម្មអាស៊ាន"(បទបង្ហាញនៅក្នុងពិធីជួបជុំយុវជននិងនិស្សិត,សាលមហោស្រពកោះពេជ្រ, ១២ មិថុនា ២០១៤)។

មកបណ្តាលប្រទេសនៅអាស៊ីអាគ្នេយ៍ បានចាកចេញពីគោលការណ៍សមាហរណកម្មនយោបាយ យោធា អោយទៅជាសមាហរណកម្មនយោបាយសេដ្ឋកិច្ចវិញ។

ក្នុងកិច្ចប្រជុំខែសីហា ឆ្នាំ១៩៦៧ នៅក្រុងបាងកក រដ្ឋមន្ត្រីការបរទេសនៃប្រទេស ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃ ហ្វីលីពីន និងសិង្ហបុរី បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (Association of Southeast Asian Nation-ASEAN)។ ដូច្នេះ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថា អាស៊ានត្រូវបានបង្កើតឡើង។[7]

### ១.១.២. គោលបំណង

គោលបំណងសំខាន់ក្នុងការបង្កើតសមាគមអាស៊ាន គឺផ្តោតការយកចិត្តទុកដាក់លើការពន្លឿនវឌ្ឍនភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ព្រមទាំងការពង្រឹងសន្តិភាព និងស្ថេរភាពក្នុងតំបន់។[8]ដោយផ្អែកលើជំពូកទី១ មាត្រា១នៃធម្មនុញ្ញអាស៊ាន គោលបំណងរបស់សមាគមអាស៊ានមានដូចតទៅ៖

១. ថែរក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ ស្ថេរភាព និងពង្រីកបន្ថែមទៀតនូវតម្លៃឆ្ពោះទៅរកសន្តិភាពក្នុងតំបន់។

២. លើកកម្ពស់ភាពរឹងមាំនៃតំបន់តាមរយៈ ការជំរុញឲ្យកាន់តែខ្លាំងថែមទៀតនូវកិច្ចសហប្រតិបត្តិការផ្នែកនយោបាយ សន្តិសុខ សង្គម និងវប្បធម៌។

៣. រក្សាតំបន់អាស៊ីអាគ្នេយ៍ ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ និងគ្មានអាវុធប្រល័យលោកផ្សេងទៀត។

៤. ធានាថាប្រជាជន និងរដ្ឋសមាជិកអាស៊ានរស់នៅប្រកបដោយសន្តិភាព ជាមួយពិភពលោកទាំងមូលក្នុងបរិយាកាសយុត្តិធម៌ ប្រជាធិបតេយ្យ និងភាពសុខដុមរមនា។

៥. បង្កើតទីផ្សាររួមមួយ និងមូលដ្ឋានផលិតកម្មរួមដែលមានស្ថេរភាព វិបុលភាព មានការប្រកួតប្រជែងខ្ពស់ និងសមាហរណកម្មសេដ្ឋកិច្ចជាមួយនឹងការសម្របសម្រួលដ៏មានប្រសិទ្ធិភាពសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ ដោយក្នុងនោះមានលំហូរ ដោយសេរីនូវ ទំនិញសេវាកម្ម និងវិនិយោគ សម្រួលចលនាពាណិជ្ជករ អ្នកមានវិជ្ជាជីវៈ អ្នកមានទេពកោសល្យ និងពលករ និងលំហូរដោយម្ចាស់ការនៃទុន។

---

[7] The ASEAN Declaration in Bangkok,08 August 1967.

[8] យួន ធារ៉ា, "ផលប្រយោជន៍ និងផលវិបាកកម្ពុជាចូលជាសមាជិកអាស៊ាន," *សម្លេងសហរដ្ឋអាមេរិក*,០១ឧសភា២០១៤, http://khmer.voanews.com/content/fifteen-years-into-asean-cambodia-membership-challenges-remain/1904759.html (បានចូលមើលចុងក្រោយ ១៤ ឧសភា ២០១៥)។

៦. កាត់បន្ថយភាពក្រីក្រ និងបង្រួមគម្លាតនៃការអភិវឌ្ឍនៅក្នុងតំបន់អាស៊ាន តាមរយៈការជួយគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការ។

៧. ពង្រឹងលទ្ធិប្រជាធិបតេយ្យ លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ ការពារ និងលើកកម្ពស់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដោយយកចិត្តទុកដាក់ចំពោះសិទ្ធិ និងការទទួលខុសត្រូវរបស់សមាជិកអាស៊ាន។

៨. ឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពទៅតាម គោលការណ៍នៃសន្តិសុខពេញលេញចំពោះការគំរាមកំហែងគ្រប់រូបភាព ឧក្រិដ្ឋកម្មឆ្លងដែន និងបញ្ហាប្រឈមនានា។

៩. លើកស្ទួយការអភិវឌ្ឍប្រកបដោយនិរន្តភាព ដើម្បីធានាការការពារបរិស្ថានតំបន់ និងនិរន្តភាពនៃធនធានធម្មជាតិ និងការអភិវឌ្ឍមរតកវប្បធម៌ និងគុណភាពនៃជីវភាពរស់នៅខ្ពស់របស់ប្រជាជន។

១០. អភិវឌ្ឍធនធានមនុស្សតាមរយៈ កិច្ចសហប្រតិបត្តិការជិតស្និទ្ធក្នុងការអប់រំ និងការសិក្សាក្នុងមួយជីវិតនិងលើផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសដើម្បីផ្តល់ជូនប្រជាជនអាស៊ាន និងការពង្រឹងសហគមន៍អាស៊ាន។

១១. លើកកម្ពស់ភាពសុខដុមរមនា និងជីវភាពរស់នៅរបស់ប្រជាជនអាស៊ាន ដោយការផ្តល់ឲ្យនូវលទ្ធភាពទទួលបានសមភាពក្នុងការអភិវឌ្ឍមនុស្ស សុខុមាលភាពសង្គម និងយុត្តិធម៌។

១២. ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការកសាងបរិស្ថានប្រកបដោយសុវត្ថិភាព សន្តិសុខ និងភាពគ្មានគ្រឿងញៀនសម្រាប់ប្រជាជនអាស៊ាន។

១៣. ជំរុញការយកចិត្តទុកដាក់ដល់ប្រជាជនអាស៊ាន ក្នុងនោះគ្រប់ផ្នែកទាំងអស់នៃសង្គមត្រូវបានលើកទឹកចិត្តឲ្យចូលរួម និងទទួលយកផលប្រយោជន៍ពីដំណើរការសមាហរណកម្ម និងការកសាងសហគមន៍អាស៊ាន។

១៤. ជំរុញអត្តសញ្ញាណអាស៊ាន តាមរយៈការជំរុញ ឲ្យចម្រើនឡើងនូវការយល់ដឹងអំពីវប្បធម៌ និងមរតកចម្រុះក្នុងតំបន់។

១៥. ថែរក្សាតួនាទីស្នូលដ៏សកម្ម របស់អាស៊ានជាកម្លាំងចលករដ៏សំខាន់ក្នុងទំនាក់ទំនង និងសហប្រតិបត្តិការរបស់ខ្លួនជាមួយដៃគូក្រៅតំបន់ក្នុងស្ថាបត្យកម្មតំបន់ ប្រកបដោយភាពបើកចំហ មានតម្លាភាព និងការរួមបញ្ចូលគ្នា។[9]

---

[9] ធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍, មាត្រា១។

ដោយយោងតាមធម្មនុញ្ញអាស៊ាន គោលបំណងដែលបានចែងក្នុងមាត្រា១ អាស៊ាន និងរដ្ឋសមាជិករបស់ខ្លួនអះអាងជាថ្មី និងប្រកាន់ខ្ជាប់នូវគោលការណ៍ជាមូលដ្ឋានដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ កិច្ចព្រមព្រៀង អនុសញ្ញា សន្ធិសញ្ញា កិច្ចស្រុះស្រួល និងលិខិតូបករណ៍ដទៃរបស់អាស៊ាន។

នៅក្នុងដំណើរការអភិវឌ្ឍប្រទេសជាសមាជិកអាស៊ានមានការលូតលាស់សេដ្ឋកិច្ចមិនដូចគ្នាទេ។ ប្រទេសសិង្ហបុរី និងប្រ៊ុយណេស្ថិតក្នុងចំណោមប្រទេសដែលមានការអភិវឌ្ឍមនុស្ស (Human Development) ខ្ពស់ជាងគេ។ ប្រទេសម៉ាឡេស៊ី ថៃ ហ្វីលីពីន និងឥណ្ឌូនេស៊ី ស្ថិតក្នុងចំណោមប្រទេសដែល មានការអភិវឌ្ឍន៍មនុស្សមធ្យម។ ដូច្នេះសមាជិកដែលមានកម្រិតសេដ្ឋកិច្ច លូតលាស់ដូចជាប្រទេសសិង្ហបុរី និងម៉ាឡេស៊ី តែងតែទទួលបានផលប្រយោជន៍ច្រើនជាងសមាជិកដែលមិនសូវលូតលាស់ ដូចជាកម្ពុជា ឡាវ វៀតណាម មីយ៉ាន់ម៉ាជាដើម។

### ១.១.៣. ការបង្កើតធម្មនុញ្ញអាស៊ាន

ធម្មនុញអាស៊ាន បង្កើតឡើងជាកិច្ចព្រមព្រៀងអន្តរជាតិ រវាងរដ្ឋសមាជិកអាស៊ីអាគ្នេយ៍ក្នុងតំបន់ដែលមានបុគ្គលភាពគតិយុត្តិ និងមានអានុភាពចាប់បង្ខំចំពោះការអនុវត្តរបស់រដ្ឋសមាជិកទាំងអស់។ ធម្មនុញអាស៊ាន ក៏ជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយក្នុងការជួយឱ្យសម្រេចឲ្យបាននូវសហគមន៍អាស៊ាន តាមរយៈការផ្តល់នូវក្របខណ្ឌស្ថាប័ន និងលក្ខន្តិកៈគតិយុត្តសម្រាប់អាស៊ាន។

តាមរយៈការជួបប្រជុំគ្នារវាងរដ្ឋមន្ត្រីការបរទេសអាស៊ានបានធ្វើឡើង នៅឯលេខាធិការដ្ឋានអាស៊ាន នៅទីក្រុងហ្សាកាតាដើម្បីកំណត់ការចូលជាធរមាននៃធម្មនុញ្ញអាស៊ាន នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៨។ ការចូលជាធរមាននៃធម្មនុញ្ញអាស៊ាន បានបង្កើតក្របខណ្ឌគតិយុត្តិថ្មីមួយ និងបង្កើតអង្គការចាត់តាំងមួយចំនួនដើម្បីជម្រុញដំណើរការកសាងសហគមន៍របស់ខ្លួន។ ធម្មនុញ្ញអាស៊ានបានក្លាយជាកិច្ចព្រមព្រៀង ដែលមានលក្ខណៈជាកាតព្វកិច្ចតាមផ្លូវច្បាប់រវាងសមាជិកអាស៊ានទាំង ១០ប្រទេស។

យោងតាមជំពូកទី១មាត្រា២វ៉ាក្យខណ្ឌទី២នៃធម្មនុញ្ញាអាស៊ាន បានកំណត់ថា អាស៊ាន និងរដ្ឋសមាជិកត្រូវអនុវត្តស្របតាមគោលការណ៍សំខាន់ៗដូចខាងក្រោម៖

- គោរពឯករាជ្យភាព អធិបតេយ្យភាព សមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិនៃរដ្ឋសមាជិកអាស៊ានទាំងអស់
- ចូលរួមការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវរួមគ្នា ក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់

- ប្រកាន់យកដំណោះស្រាយជម្លោះដោយសន្តិវិធី
- គោរពរដ្ឋសិទ្ធិរបស់រដ្ឋមាជិកនីមួយៗ ក្នុងការដឹកនាំអត្ថិភាពជាតិរបស់ខ្លួន ដោយពុំមានការជ្រៀតជ្រែកពីខាងក្រៅ ការធ្វើវិទ្ធង្សនា និងការបង្ខិតបង្ខំ
- ប្រកាន់ខ្ជាប់នូវនីតិរដ្ឋ អភិបាលកិច្ចល្អ គោលការណ៍ប្រជាធិបតេយ្យ និងរដ្ឋាភិបាលអាស្រ័យដោយរដ្ឋធម្មនុញ
- គោរពសេរីភាពមូលដ្ឋាន លើកស្ទួយ និងការពារសិទ្ធិមនុស្ស និងលើកកម្ពស់យុត្តិធម៌សង្គម
- គោរពវប្បធម៌ផ្សេងៗគ្នា ភាសា និងសាសនារបស់ប្រជាជនអាស៊ាន ដោយសង្កត់ធ្ងន់ទៅលើតម្លៃរួម ក្នុងស្មារតីឯកភាពក្នុងពហុភាព
- ប្រកាន់ខ្ជាប់នូវវិធានពាណិជ្ជកម្មពហុភាគី និងរបបផ្អែកលើមូលដ្ឋានច្បាប់របស់អាស៊ាន ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធិភាពនូវកិច្ចខិតខំប្រឹងប្រែងផ្នែកសេដ្ឋកិច្ច និងកាត់បន្ថយជាវិជ្ជមានឆ្ពោះទៅលុបបំបាត់របាំងទាំងស្រុង សម្រាប់សមាហរណកម្មសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចទីផ្សារ។[10]

## ១.២. តើអ្វីជាសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន?

**សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន២០១៥** គឺ ជាការកសាងទីផ្សារតែមួយ និងការផលិតជាមូលដ្ឋានជាមួយនឹងគោលបំណងធ្វើឲ្យទីផ្សាររបស់អាស៊ានកាន់តែសំបូរដៃគូពាណិជ្ជកម្ម និងមានការប្រកួតប្រជែងកាន់តែខ្លាំងដែលដំណើរការនេះមានឈ្មោះថា ការកសាងសហាគមន៍សេដ្ឋកិច្ចអាស៊ាន(AEC= ASEAN Economic Community)។[11]

សហាគមន៍សេដ្ឋកិច្ចអាស៊ាន គឺជាការបង្កើតអាស៊ានដែលមានទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ ជាមួយគោលដៅធ្វើអោយអាស៊ាន ពោរពេញទៅដោយថាមពល និងការប្រកួតប្រជែង។[12]

សមាហាគមន៍សេដ្ឋកិច្ចអាស៊ាន មានសសរស្តម្ភ ០៤ គឺ ទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ តំបន់ដែលមានសេដ្ឋកិច្ចប្រកួតប្រជែង ការអភិវឌ្ឍសេដ្ឋកិច្ចដោយសមធម៌ និងចុងក្រោយគឺការឈានទៅរកសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក។

[10] ធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍, មាត្រា២។

[11] ទេព អ៊ីវិសាល, "តើអ្វីជាសមាហរណកម្មអាស៊ាន២០១៥," *ថ្មីថ្មី*, ២០ តុលា ២០១៤, http://www.themythey.com.kh.html (បានចូលមើលចុងក្រោយ ១៥ឧសភា ២០១៥)។

[12] ស៊ុន ចាន់ថុល, "ការត្រៀមសម្រាប់សមាហរណកម្មសហាគមន៍សេដ្ឋកិច្ចអាស៊ានឱកាសនិងបញ្ហាជុំវិញការធ្វើអាជីវកម្ម" (បទបង្ហាញនៅក្នុងវេទិកាវិស័យឯកជនតាមបណ្តាខេត្ត, ២៣-២៤ កុម្ភៈ ២០១៥)។

ទោះជាយ៉ាងណាក៏ដោយសមាហរណកម្មអាស៊ាន នឹងនាំអោយមានលំហូរដោយសេរីទំនិញ សេវា វិនិយោគ មូលធន និងពលកម្មជំនាញ ក្រោមក្របខ័ណ្ឌនៃការយល់ព្រមរវាងសមាជិកទាំងអស់ដែលវានឹងផ្តល់ជាប្រយោជន៍សម្រាប់យុវជន និងកម្ពុជា។ ជាបឋមនៃសមាហរណកម្មអាស៊ាន គេបានសន្មតជំនាញចំនួន ៨ ដែលចេញចូលបានដោយសេរី ហើយការហូរចូលបានគឺអាស្រ័យទៅលើកម្រិតនៃការអប់រំ ឬ គុណវុឌ្ឍិនៃប្រទេសដែលជាសមាជិកចង់បាន។ ការងារជំនាញទាំង៨នោះរួមមាន វិស្វកម្ម និងបច្ចេកទេស ស្ថាបត្យកម្ម វិទ្យាសាស្ត្រសុខាភិបាល គិលានុបដ្ឋាយិការ គណនេយ្យ ជំនាញវាស់ស្ទង់ផ្លូវ និងសំណង់ ទេសចរណ៍ និងចុងក្រោយគឺទន្តពេទ្យ។ ជំនាញទាំងនេះ គឺជាជំនាញដែលប្រទេសជាសមាជិក បានឯកភាពគ្នាអោយមានការទទួលស្គាល់គ្នាទៅវិញទៅមកហើយគេមានតម្រូវការគុណវុឌ្ឍិរួមមួយ ដើម្បីកំណត់ពីសមត្ថភាពរបស់ធនធានមនុស្ស។[13]

[13] ហៃ ហ៊ុនឡេង, បទសម្ភាសដោយ កង កល្យាណ, *ទូរទស្សន៍ ស៊ី ធី អិន*, ២៥ មិថុនា ២០១៥។

# ជំពូកទី២

# គុណសម្បត្តិនៃសមាហរណកម្ម និងស្ថានភាពយុវជនកម្ពុជា

ប្រទេសកម្ពុជា ជាប្រទេសដែលរួមរស់ដោយសន្តិសហវិជ្ជមានជាមួយ បណ្តាប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក ហើយក៏មិនឈ្លានពាន មិនជ្រៀតជ្រែងកិច្ចការផ្ទៃក្នុងប្រទេសដទៃឡើយ។[14] បន្ទាប់ពីកម្ពុជា បានដោះស្រាយនូវវិបត្តិនយោបាយ ព្រមទាំងរក្សាបាននូវសុខសន្តិភាព និងស្ថេរភាពសង្គមនយោបាយមក អាស៊ានបានសម្រេចទទួលយកកម្ពុជាជាសមាជិកពេញសិទ្ធិនៅថ្ងៃទី ៣០ខែ មេសា ឆ្នាំ ១៩៩៩ ។

ក្រោយពីបានចូលជាសមាជិកសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍រយៈពេលបីឆ្នាំមក កម្ពុជាបានត្រូវចាត់តាំងឲ្យធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ានជាលើកដំបូងនៅឆ្នាំ២០០២-២០០៣ និងជាលើកទីពីរនៅក្នុងឆ្នាំ២០១២-២០១៣។ ការឈានជើងចូលទៅសហគមន៍នេះ មិនមែនមានភាពងាយស្រួលឡើយ ដោយកម្ពុជាត្រូវធ្វើកំណែទម្រង់ជាច្រើន ដើម្បីឲ្យស្របតាមការទាមទារ ឬលក្ខខ័ណ្ឌដែលជាកាតព្វកិច្ចក្នុងនាមខ្លួនជាសមាជិក។

នៅរយៈពេលដ៏ខ្លីខាងមុខ ចុងឆ្នាំ២០១៥នេះ សមាហរណកម្មសេដ្ឋកិច្ចអាស៊ាននឹងត្រូវចាប់ផ្តើម ដូច្នេះសមាហរណកម្មនឹងនាំផលប្រយោជន៍ដល់យុវជនកម្ពុជា ជាច្រើន ហើយទន្ទឹមនឹងនេះ យុវជនខ្លួនឯងផ្ទាល់ក៏ត្រូវត្រៀមលក្ខណៈដើម្បីសម្របខ្លួនទៅនឹងសមាហរណកម្មនោះផងដែរ។

## ២.១. គុណសម្បត្តិ

បើគ្មានការប្រែប្រួលទេ នៅចុងឆ្នាំ២០១៥ អាស៊ាននឹងធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន។ វានឹងបើកចំហអោយមានលំហូរទំនិញ សេវាកម្ម មូលធន និងទុនវិនិយោគពីប្រទេសមួយទៅប្រទេសមួយទៀតដោយសេរី។[15] សមាហរណកម្ម នឹងនាំផលប្រយោជន៍ដល់យុវជនកម្ពុជាជាច្រើនក្នុងការប្រកួតប្រជែងជាមួយប្រទេសក្នុងតំបន់អាស៊ាន និងឆាកអន្តរជាតិ ព្រោះថាពលរដ្ឋដែលមានជំនាញច្បាស់លាស់នៃប្រទេសជាសមាជិកអាស៊ាន នឹងអាចធ្វើការនៅក្នុងប្រទេសជាសមាជិកដោយសេរី។ សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន គឺជាទិសដៅនៃប្រទេសជាសមាជិកក្នុងការបង្កើតទីផ្សាររួមមួយដើម្បីសម្រួលដល់ការវិនិយោគ និងពាណិជកម្មនៃបណ្តាប្រទេសជាសមាជិកអោយ

[14] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា៥៣។

[15] អ៊ឹម រចនា, យុវជនខ្មែរត្រូវត្រៀមខ្លួនជ្រែកទីផ្សារការងារ ពេលអាស៊ានប្រែខ្លួនជាសហគមន៍តែមួយ, *វិទ្យុបារាំងអន្តរជាតិជាខេមរភាសា*, ០៣ មិថុនា ២០១៥, http://km.rfi.fr/cambodia/khmer-youth-labor-ready-interference-asean-substantially-same-community-03-06-2015 (បានចូលមើលចុងក្រោយ ០៤ មិថុនា ២០១៥)។

មានសេដ្ឋកិច្ចជឿនលឿន និងមានប្រសិទ្ធិភាពខ្ពស់។ តាមរយៈសមាហរណកម្មនេះ វានឹងឈានទៅរកការដករបាំងពន្ធគយ ដែលអាចទាក់ទាញវិនិយោគិនបរទេសជាច្រើនធ្វើការវិនិយោគក្នុងតំបន់អាស៊ាន។ ការវិនិយោគកើនឡើង វាទាក់ទាញនូវកំលាំងពលកម្ម និងធនធានមនុស្សជាច្រើន ដែលជាឱកាសដ៏ល្អមួយសម្រាប់យុវជនកម្ពុជា ក្នុងការទទួលបានការងារដែលមានប្រាក់ខែខ្ពស់ និងមានបទពិសោធច្រើនជាមួយការងារជាក់ស្ដែង។

**ចំនុចខ្លាំងរបស់យុវជនយើង គឺអ្នករៀនមានសមត្ថភាពភាសា រីឯអ្នកមិនរៀនសូត្រអាចលក់កម្លាំងពលកម្ម។**[16]

ថ្វីបើសមាហរណកម្មអាស៊ាន មិនទាន់ចូលជាផ្លូវការ ប៉ុន្តែប្រទេសជាសមាជិកបានចូលរួមជាសកម្មភាពរួចទៅហើយក្នុងការចូលសមាហរណកម្មអាស៊ាន។ យើងមើលឃើញថាសព្វថ្ងៃនេះមានក្រុមហ៊ុនជាច្រើនបានវិនិយោគក្នុងកម្ពុជា ដែលបានដោះដូរ និងសេវាកម្មគ្នាទៅវិញទៅមក ប៉ុន្តែនេះវាគ្រាន់តែជាផ្នែកតូចមួយប៉ុណ្ណោះនៃសមាហរណកម្មអាស៊ាន។ នៅពេលសមាហរណកម្មអាស៊ានពិតប្រាកដ វាបានផ្ដល់ឱកាសមួយដ៏ធំសម្រាប់យុវជន គឺឱកាសការងារ។ សមាហរណកម្មអាស៊ាន ត្រូវបានគេសម្លឹងមើលឃើញថានឹងផ្ដល់ជាប្រយោជន៍ បីសំខាន់ សម្រាប់យុវជនកម្ពុជា គឺ (១). ឱកាសការងារ ដែលអាចផ្ដល់ឱកាសសម្រាប់យុវជនមានបំណងក្លាយខ្លួនជាសហគ្រិន អាចចាប់ផ្ដើមធ្វើអាជីវកម្ម ឬជំនួញផ្សេងៗ (២). ការកសាងទំនាក់ទំនង ការទទួលបានចំណេះដឹងពីវប្បធម៌របស់ប្រទេសនីមួយៗ និងចុងក្រោយ គឺ(៣) ផ្លាស់ប្ដូរបទពិសោធន៍ក្នុងការសិក្សា និងឱកាសការសិក្សា។

### ២.១.១. ឱកាសការងារ

កម្ពុជា ជាប្រទេសដែលអំណោយផល សម្រាប់ចូលរួមក្នុងកម្លាំងពលកម្ម នៅពេលដែលកម្ពុជាចូលសមាហរណសេដ្ឋកិច្ចអាស៊ាន។ កម្ពុជាមានយុវជន ដែលមានអាយុក្រោម២៥ឆ្នាំ រហូតដល់ទៅជាង៥២ភាគរយ។ លើសពីនេះទៅទៀត បើនិយាយពីប្រជាជនវ័យក្មេងក្រោម៣៥ឆ្នាំ គឺកម្ពុជាមានរហូតទៅដល់ជិត៧០ភាគរយ។[17] យុវជនកម្ពុជា នឹងក្លាយជាដៃគូប្រកួតប្រជែងលើទីផ្សារការងារនៃបណ្ដាប្រទេសជាសមាជិក។ សម្រាប់យុវជនដែលមិនសូវមានចំណេះដឹង និងជំនាញ ក៏មានឱកាសខ្ពស់ដែរក្នុងការទទួលបានការងារ ក្នុងបណ្ដាប្រទេសជាសមាជិកដែលមាន

---

[16] អ៊ុង វ៉ាន់ធឿន, បទសម្ភាសដោយ ទេព សុរ៉ាវី, *វិទ្យុអាស៊ីសេរី*, ២១ ធ្នូ ២០១៤។

[17] អ៊ឹម រចនា, យុវជនខ្មែរត្រូវត្រៀមខ្លួនជ្រែកទីផ្សារការងារ ពេលអាស៊ានប្រែខ្លួនជាសហគមន៍តែមួយ, *វិទ្យុបារាំងអន្តរជាតិជាខេមរភាសា*, ០៣ មិថុនា ២០១៥, http://km.rfi.fr/cambodia/khmer-youth-labor-ready-interference-asean-substantially-same-community-03-06-2015 (បានចូលមើលចុងក្រោយ ០៤មិថុនា ២០១៥)។

សេដ្ឋកិច្ចរីកចម្រើន ពីព្រោះប្រទេសទាំងនោះមានតម្រូវការកំលាំងពលកម្មច្រើន ហើយមានតម្លៃទាប។ យុវជនដែលមានជំនាញច្បាស់លាស់ និងមានចំណេះដឹងភាសាអង់គ្លេស អាចទទួលបានការងារកម្រិតខ្ពស់ មានន័យថាពួកគេអាចទទួលបានប្រាក់ខែដែលមានកម្រិតខ្ពស់ដូចកម្លាំងពលកម្មនៃប្រទេសដទៃដែរ។ យុវជនដែលចាប់យកជំនាញវិជ្ជាជីវៈ ឬ ជំនាញបច្ចេកទេស គឺជាតម្រូវការពលកម្មក្នុងវិស័យឧស្សាហកម្មដ៏ច្រើនលើសលប់ ស្របពេលដែលវិនិយោគិន កំពុងស្វែងរកទីផ្សារពលកម្មមានជំនាញច្បាស់លាស់ ហើយយុវជនអាចទទួលបាននូវចំណូលខ្ពស់ ដែលវាបានផ្ដល់ឱកាសអោយយុវជនយើងអាចបង្កើននូវជំនាញ ដើម្បីទទួលបានប្រាក់ខែសមរម្យ។ សមាហរណកម្មនេះនឹងធ្វើអោយយុវជនកម្ពុជាមានឱកាសស្មើគ្នា ក្នុងបណ្ដាប្រទេសជាសមាជិក ដើម្បីទទួលបានការងារមួយដែលសមរម្យ។

កម្ពុជា គឺជាប្រទេសដែលទាក់ទាញការវិនិយោគ និងបង្កើនទីផ្សារការងារ។ នៅពេលដែលអាស៊ានក្លាយជាទីផ្សាររួមហើយ ព្រំដែនពន្ធគយរវាងប្រទេសជាសមាជិកត្រូវបានលុបបំបាត់ កម្ពុជាអាចក្លាយជាទីតាំងផលិតដ៏មានអំណាយផលមួយសម្រាប់រោងចក្រ និងសហគ្រាសពីប្រទេសជាច្រើន ពីព្រោះថាតម្លៃពលកម្មនៅកម្ពុជាមានតម្លៃទាប បើធៀបជាមួយបណ្ដាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនក្នុងចំណោមបណ្ដាប្រទេសជាសមាជិក ដូចជា សឹង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ជាដើម ហើយទំនិញ និងផលិតផលផ្សេងៗដែលនាំចេញ ដោយគ្មានឧបសគ្គទៅប្រទេសជាសមាជិក។ ម៉្យាងទៀត យុវជនមានឱកាសក្លាយជាសហគ្រិនក្នុងការធ្វើអាជីវកម្មឬ ជំនួញផ្សេងបានទៀតផង ដែលអាចប្រកួតប្រជែងជាមួយប្រទេសជាសមាជិកបាន តាមរយៈការបើកចំហរទីផ្សាររួមមួយ។

### ២.១.២. ទំនាក់ទំនង និងវប្បធម៌

លំហូរសេរី នៃកម្លាំងពលកម្ម នឹងធ្វើអោយយុវជនកម្ពុជាមានទំនាក់ទំនងល្អជាមួយសង្គមតាមរយៈវប្បធម៌ ប្រពៃណី ទំនៀមទំលាប់នៃបណ្ដាប្រទេសជាសមាជិក។ យុវជនដែលមានការយល់ដឹងពីសង្គមមួយបាន វានឹងជួយដល់ពួកគេក្នុងការសម្របខ្លួនជាមួយបរិបទនៃសង្គមមួយទៀតដែលយុវជនកម្ពុជាមិនដែលបានជួបប្រទះ។ កន្លងមកយុវជនកម្ពុជាត្រូវបន្សាំខ្លួនជាមួយបរិស្ថាន និងវប្បធម៌ ដោយប្រើប្រាស់រយៈពេលវែង ដើម្បីបំពេញការងារ ឬការរស់នៅប្រទេសដទៃ។ ការយល់ដឹងពីអន្តរវប្បធម៌ វាជួយសម្រួលដល់ចរន្តការងារដែលសមស្របបរិបទនៃការងារ និងវប្បធម៌នៃប្រទេស ដែលយុវជនកម្ពុជាបានបំពេញការងារ។ ឧទាហរណ៍៖ វៀតណាមជាប្រទេសមួយដែលធ្វើការងារមានភាពរហ័ស កម្ពុជាពិបាកធ្វើការជាមួយវៀតណាម តែអាចធ្វើការជាមួយ

ថៅកែជនជាតិថៃបានដោយសាប្រទេសទាំងពីរមានវប្បធម៌ស្រដៀងគ្នា។ គេសង្កេតមើលឃើញថាអ្នកដែលមានការយល់ដឹង ឬ ចំណេះដឹងទូលំទូលាយវប្បធម៌នៃប្រទេសមួយពួកគេមានភាពរហ័សរហួន និងឈ្លាសវៃជាង។[18]

## ២.១.៣. បទពិសោធ និងបង្កើនចំណេះដឹង

ថ្វីបើប្រទេសទាំង១០ នៃសមាជិកអាស៊ាននិយាយភាសាផ្សេងគ្នា ប៉ុន្តែភាសាអង់គ្លេសនៅតែជាភាសាគោលសម្រាប់អោយប្រទេសជាសមាជិកប្រាស្រ័យទាក់ទងគ្នា។ យុវជនកម្ពុជាក៏អាចបង្កើនចំណេះដឹងផ្នែកភាសារបស់ខ្លួនអោយកាន់តែប្រសើរឡើងថែមទៀត។ ចំណេះដឹងភាសានេះគឺជាចំនុចសំខាន់ក្នុងទំនាក់ទំនងការងាររបស់យុវជនយើង ជាមួយយុវជនផ្សេងទៀត និងផ្លាស់ប្តូរបទពិសោធគ្នាទៅវិញទៅមក។ នៅប្រទេសម៉ាឡេស៊ី សឹង្ហបុរី និងភីលីពីន បានចាប់យកភាសាអង់គ្លេស ជាផ្នែកមួយក្នុងការអភិវឌ្ឍប្រទេស ធ្វើអោយពួកគេមានការរីកចម្រើនទាំងផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ។ ការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ពីប្រទេសទាំងនោះ នឹងជួយដល់យុវជនកម្ពុជាក្នុងកាអភិវឌ្ឍវិស័យបច្ចេកវិទ្យា និងវិស័យជាច្រើនទៀត អោយមានការរីកចម្រើនឡើង។

**យើងដើរតាមអ្នកខ្លាំង យើងនឹងខ្លាំងដូចគេអញ្ចឹង។ នេះហើយដែលយើងគួរចូលក្នុងសមាហរណកម្មអាស៊ាន។**[19]

**ដំណាក់កាលនេះ វាជាដំណាក់កាលយើងចាប់ក្រេបជញ្ជក់ចំណេះ ពីអ្នកជិតខាង ប៉ុន្មានឆ្នាំក្រោយមក ពេលដែលយើងមានសមត្ថភាពស្មើហើយ ទាំងគេទាំងយើងមិនទៅរកស៊ីជាមួយអ្នកឆ្ងាយទេ។**[20]

សមាហរណកម្មនេះ នឹងក្លាយជាកាតាលីករ ដែលជំរុញអោយយុវជនកម្ពុជាយើងមានការខំប្រឹងប្រែង ដោយមិនអោយមានគំលាតឆ្ងាយពីបណ្តាប្រទេសជាសមាជិកដទៃទៀតឡើយ។ កាតាលីករនេះ ប្រៀបដូចជាសមាសភាពម្យ៉ាង ដែលធ្វើអោយសារធាតុគីមីមានប្រតិកម្មគីមីបានឆាប់រហ័ស។ ដូចនេះ តាមរយៈសមាហរណកម្មវានឹងជួយអោយយុវជនយើងរៀនសូត្រ ពីគំនិតថ្មី និងអភិវឌ្ឍខ្លួនអោយបានឆាប់រហ័សជាងមុន។

[18] បណ្ឌិត កែម ឡី (អ្នកវិភាគ និងសិក្សាស្រាវជ្រាវសង្គម), បទសម្ភាសដោយ លឹម ម៉ីលី, ១៩ មិថុនា ២០១៥។
[19] បណ្ឌិត កែម ឡី (អ្នកវិភាគ និងសិក្សាស្រាវជ្រាវសង្គម), បទសម្ភាសដោយ លឹម ម៉ីលី, ១៩ មិថុនា ២០១៥។
[20] បណ្ឌិត សុក ស៊ីផាន់ណា, ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI), បទសម្ភាសន៍ដោយជី វីតា, *វិទ្យុអាស៊ីសេរី*, ២៨ កុម្ភៈ ២០១៤។

## ២.២. ស្ថានភាពយុវជន

នៅប្រទេសកម្ពុជាក្នុងបរិបទសង្គម វប្បធម៌ និងនយោបាយពាក្យថា **យុវជន** គឺជាបុរស និងស្ត្រីដែលមានសញ្ជាតិជាខ្មែរពីអាយុ ១៥ ដល់ ៣០ឆ្នាំ នៅលីវ ឬរៀបការហើយ នេះបើយោងតាមជំរឿនទូទៅនូវប្រជាសាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ យុវជនមាន៣៣ភាគរយ នៃចំនួនប្រជារាស្ត្រសរុប។[21]

យុវជន ជាធនធានគន្លឹះដ៏សំខាន់ និងមានតម្លៃក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងការរក្សាសន្តិភាពទាំងបច្ចុប្បន្ន ទាំងអនាគត និងជាទំពាំស្នងឬស្សីដែលសង្គមជាតិយើងចង់បាននូវឫស្សីដែលល្អមានគុណភាព។

ការអប់រំពិតជាមានសារៈសំខាន់ណាស់ចំពោះអ្នកសិក្សាគ្រប់រូប ហើយប្រទេសជាតិមានការអភិវឌ្ឍន៍រុងរឿងទៅបានគឺអាស្រ័យធនធានមនុស្សនៅប្រទេសកម្ពុជាជាពិសេស នោះគឺយុវជនតែម្តង។

ប៉ុន្មានឆ្នាំចុងក្រោយនេះប្រព័ន្ធអប់រំនៅប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ហើយយុវជនមានបំណងចង់ទទួលយកការសិក្សា រៀនសូត្រនូវអ្វីថ្មី ឬជំនាញថ្មីៗបន្ថែមទៀត។ ប៉ុន្តែនិស្សិតមួយចំនួនធំ ជ្រើសរើសបន្តការសិក្សាជំនាញ ដូចជា គណនេយ្យ ទីផ្សារ ហិរញ្ញវត្ថុនិង ធនាគារ តែតម្រូវការជំនាញដែលត្រូវការអនុវត្តជាក់ស្តែងនៅក្នុងផ្នែកសំខាន់ៗផ្សេងទៀតនោះ គឺបច្ចេកវិទ្យាវិស្វ័យកម្ម ដែលមានការខ្វះខាតនូវធនធានមនុស្ស។ ការសិក្សានៅមហាវិទ្យាល័យមិនប្រាកដថានិសិត្សអាចទទួលបាននូវចំណេះដឹងពេញលេញ ជាក់ច្បាស់នោះទេ គឺពួកគេអាចត្រឹមតែទទួលបាននូវទ្រឹស្តី ចំណេះដឹងជាមូលដ្ឋានតែប៉ុណ្ណោះ រីឯការអនុវត្តជាក់ស្តែងវិញគឺពួកគេពុំបានយល់ដឹងពីបរិបទការងារ ឬសង្គមទេ។

អ្នកវិភាគមួយចំនួនបាននិយាយថា កម្ពុជាប្រហែលជាដើរក្រោយគេ ប្រសិនបើកម្លាំងពលកម្មដែលមានស្រាប់នេះមិនមានជំនាញដែលទីផ្សារកំពុងត្រូវការ ហើយអត្ថប្រយោជន៍ផ្សេងៗដែលត្រូវបានពីការធ្វើសមាហរណកម្មនឹងធ្លាក់ចុះឬបាត់បង់ពីភាពជាសមាជិករបស់ខ្លួន ដោយសារតែសមត្ថភាពរបស់កម្លាំងពលកម្ម និងការអប់រំដល់ពួកគាត់គ្មានប្រសិទ្ធភាព។ ជារៀងរាល់ឆ្នាំ មានយុវជនរាប់ពាន់នាក់បោះជំហ៊ានចូលទីផ្សារពលកម្ម ប៉ុន្តែអ្វីដែលយុវជនទាំងនោះមាននៅក្នុងខ្លួនដូចជា ចំណេះដឹង សមត្ថភាព ជំនាញ-ល- គឺវាមិនទាន់សមស្របនឹងតម្រូវការបច្ចុប្បន្ន។

ដូចនេះ កម្ពុជាចាំបាច់ត្រូវតែធ្វើកំណែទម្រង់ប្រព័ន្ធអប់រំស៊ីជម្រៅដើម្បីឱ្យមានគុណភាព និងប្រសិទ្ធិភាពឆ្លើយតប បើមិនដូច្នេះទេ កម្ពុជា ជាពិសេសយុវជននឹងជួបប្រទះ ឬប្រឈមនឹងបញ្ហាជា

[21] គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា, ២៤ មិថុនា ២០១១។

ច្រើនក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ក៏ដោយសារតែការហូរចូលនូវពលករបរទេសដែលមានជំនាញមកប្រកួតប្រជែងជាមួយកម្ពុជា។

### ២.២.១. ស្ថានភាពយុវជនក្រោយសង្គ្រាម និងបច្ចុប្បន្ន

វិស័យអប់រំធនធានមនុស្សបានចាប់ផ្តើមរីកចម្រើន ចាប់តាំងពីទស្សវត្សទី៦០។ វាជាឆ្នាំដែលបានចាប់ផ្តើមកកើតដំបូងនូវសាកលវិទ្យាល័យ។ ធនធានមនុស្សជាច្រើន ត្រូវបានយកទៅបណ្តុះបណ្តាល ដែលប្រកបដោយជំនាញ ក្នុងការបំពេញការងារ។ ធនធានមនុស្សនាសម័យកាលនោះត្រូវបានមើលឃើញថាពិតជាមានសន្ទុះខ្លាំងក្នុងចំណោមប្រទេសនៅអាស៊ីមួយចំនួន។

កម្ពុជា ជាប្រទេសមួយបានធ្លាក់នៅក្នុងសង្គ្រាមស៊ីវិលអូសបន្លាយជាង៣ទសវត្ស មុននឹងទទួលបានសន្តិភាពក្នុងទសវត្សរ៍ទី៩០។ បញ្ហាដែលចោទឡើង ក្រោយការដួលរលំរបប ប៉ុល ពត មានច្រើនឥតគណនា ដូចជា ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច និងវប្បធម៌ត្រូវបានបំផ្លាញ។[22] សង្គ្រាមបានសម្លាប់អ្នកចេះដឹងខ្មែរ ស្ទើរដល់ចំណុចសូន្យ។ ចំណែកអ្នកដែលនៅសេសសល់ បានមីម្មាខំប្រឹងកសាងប្រទេសចាប់ពីបានដៃទទេ។ ការស្តាបនាប្រទេសដែលស្ទើរតែខ្ទេចខ្ទាំទាំងស្រុងនេះមិនមែនចំណាយពេលខ្លីធ្វើបាននោះទេ វាទាមទាររយៈពេលវែងក្នុងការសម្រេចបាននូវគោលដៅនេះ។ ជាពិសេស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិស្សិតបញ្ញវ័ន្ត និងអ្នកមានចំណេះដឹងជាច្រើនត្រូវបានសម្លាប់ សូម្បីតែនិស្សិតបញ្ញវ័ន្តនៅក្រៅស្រុក ក៏ត្រូវបានរដ្ឋាភិបាល ប៉ុល ពត អំពាវនាវអោយចូលក្នុងស្រុក និងសម្លាប់ចោលដែរ។ ក្រោយពីរបបនេះដួលរលំ កម្ពុជាត្រូវបន្តធ្វើសង្គ្រាមក្នុងស្រុកជាមួយទាហ៊ានខ្មែរក្រហមដែលតស៊ូរហូតដល់ឆ្នាំ១៩៩៨។ ប៉ុន្តែអ្វីដែលជាបញ្ហាក្រោយការដួលរលំ ការបាត់បង់ធនធានមនុស្សដែលមានជំនាញពិតប្រាកដ គឺពិតជាមានទំហំធំដែលពិបាកវាស់វែង។ ប្រទេសកម្ពុជា ត្រូវចាប់ផ្តើមចេញពីចំនុចមួយដ៏ពិបាកគឺបញ្ហាបណ្តុះបណ្តាលធានធានមនុស្ស។ សួរថាតើនៅក្នុងចន្លោះអន្តរកាលនេះតើរដ្ឋាភិបាលគួរតែចាត់ទុកវិស័យអប់រំជាអាទិភាពដើម្បីឲ្យសម្រេចគោលដៅរបស់ខ្លួនបាន? រាជរដ្ឋាភិបាលបានចាប់ផ្តើមយកគោលនយោបាយ "អ្នកចេះច្រើនបង្រៀនអ្នកចេះតិច ឯអ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ"។ វិស័យអប់រំនេះទៀតសោត ត្រូវបានរាជរដ្ឋាភិបាលដាក់ជាវិស័យអាទិភាពដើម្បីអភិវឌ្ឍធនធានមនុស្ស។ យុវជននាពេលនោះ ពិតជាទទួលបានចំណេះដឹងតិចតួចណាស់។ បើគិតពីឆ្នាំដែលមនុស្សដែលចាប់ផ្តើមកើតនាទស្សវត្សទី៨០ រហូតមកពេលបច្ចុប្បន្ននេះ ពួកគេបានក្លាយជាយុវជនដែលពោរពេញទៅដោយកម្លាំងពលកម្មសម្រាប់ជាធនធានមនុស្សរបស់ប្រទេសជាតិ។

[22] វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា* (២០០៨), ១៩៦។

ដោយសារបញ្ហាភាពក្រីក្រ សង្គ្រាមស៊ីវិលដែលបានអូសបន្លាយរហូតដល់ឆ្នាំ១៩៩៨ ក្រោយពីកម្ពុជាបានសន្តិភាពពេញលេញ កម្ពុជាត្រូវដោះស្រាយបញ្ហាជាច្រើន ដូចជា បញ្ហាមីន ជនពិការដោយសារសង្គ្រាម វិបត្តិដីធ្លី កង្វះសាលារៀនចំណេះដឹងទូទៅ និងជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈ កង្វះគ្រូបង្រៀន បញ្ហាអនក្ខរកម្ម ខ្វះជំនួយ និងបញ្ហាប្រាក់បៀវត្ស។ បញ្ហាទាំងអស់នេះហើយដែលបានធ្វើអោយវិស័យអប់រំនៅកម្ពុជានៅមានកម្រិត។ បញ្ហាទាំងនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការអភិវឌ្ឍវិស័យធនធានយុវជន ក៏ដូចជា ការកំណែទម្រង់វិស័យអប់រំ។ ប្រជាជនដែលរស់នៅតំបន់ដាច់ស្រយាល ខ្វះសាលារៀន ហើយគុណភាពនៃការអប់រំក៏មិនទាន់អាចទទួលស្គាល់បាន។ រាជរដ្ឋាភិបាល បានជម្រុញអោយយុវជនទាំងអស់ទទួលបានការអប់រំយ៉ាងតិចណាស់ត្រឹមថ្នាក់ទី៩ ម៉្យាងដើម្បីទទួលបានធនធានមនុស្សច្រើន ការប្រលងបញ្ចប់នានាមិនសូវបានរឹតបន្តឹង និងមានភាពយោគយល់ច្រើន។ ការធ្វើបែបនេះ ក៏អាចជួយអោយសិស្ស និងយុវជនបោះបង់ការសិក្សាពាក់កណ្តាលទីនៅពេលខ្លួនប្រលងធ្លាក់មានអត្រាទាប។ ប្រសិនបើយុវជនទាំងនោះប្រលងធ្លាក់ ពួកគេអាចបោះបង់ការសិក្សា ទៅធ្វើការដោយប្រើកំលាំងដើម្បីស្វែងរកចំណូលសម្រាប់គ្រួសារ យុវជនខ្លះបានសម្រេចបញ្ចប់ ការសិក្សារបស់ខ្លួនត្រឹមថ្នាក់ទី៩ ហើយទៅធ្វើការងាររោងចក្រកាត់ដេរ ដោយមិនបានចាប់ជំនាញបច្ចេកទេស ឬ បណ្តុះបណ្តាលវិជ្ជាជីវៈក្រោយពីការបោះបង់ការសិក្សា។ យុវជនជារៀងរាល់ឆ្នាំដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ និងថ្នាក់ទី១២មានចំនួនបរិមាណច្រើន ប៉ុន្តែគុណភាពនៅមានកម្រិត។ ម៉្យាងទៀត ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជំនាញបច្ចេកទេសនៅមិនទាន់មានភាពរីកចម្រើន។
ដោយសារបញ្ហាប្រវត្តិសាស្ត្រនេះហើយ បានជម្រុញអោយយុវជនកម្ពុជាដែលទទួលបានការបណ្តុះបណ្តាលមានតែចំនួនបរិមាណ មិនទាន់មានគុណភាពអាចប្រកួតប្រជែងបាន។

នាពេលបច្ចុប្បន្ន វិស័យអប់រំមានការរីកលូតលាស់យ៉ាងខ្លាំង កម្រិតមត្តេយ្យសិក្សា រហូតដល់ឧត្តមសិក្សាបានរីកចម្រើន ទាំងវិស័យឯកជន និងវិស័យសាធារណៈ។ យុវជនត្រូវបានទទួលការបណ្តុះបណ្តាលជាច្រើនទាំងលើ វិស័យជំនាញ និងភាសា ប៉ុន្តែវាក៏នូវមានចំនុចខ្វះខាតច្រើនសម្រាប់យុវជនយើង។ យុវជនដែលរស់នៅទីជនបទ ទទួលបានការបណ្តុះបណ្តាលតិចតួចលើភាសាបរទេស ចំពោះគ្រួសារដែលមានស្ថានភាពក្រីក្រ ពួកគេប្រឈមនឹងការបោះបង់ការសិក្សានៅថ្នាក់ឧត្តមសិក្សា ហើយងាកមកចាប់យកជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែចំនួននេះវានៅមានកម្រិត មិនទាន់មានលក្ខណៈរីកសុះសាយនៅទូទាំងប្រទេសឡើយ។ យុវជនមានជម្រើសច្រើនក្នុងការទទួលបានជំនាញ និងចំណេះដឹងគ្រប់គ្រាន់បើធៀបទៅសម័យសង្គ្រាម។

ការបើកទូលាយផ្នែកអប់រំបានធ្វើអោយយុវជនមានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ ប៉ុន្តែយើងនឹងសិក្សាពីស្ថានភាពយុវជនបច្ចុប្បន្នតាមរយៈការអង្កេតៈ

### ២.២.២. ការយល់ដឹងរបស់យុវជនកម្ពុជាអំពីទីផ្សារពលកម្មតាមរយៈការអង្កេត

នៅក្នុងការសរសេរអត្ថបទស្រាវជ្រាវនេះ នាងខ្ញុំបានធ្វើការស្ទង់មតិ (Survey) និងសាកសួរយោបល់ពីសំណាក់មិត្តយុវជនចំនួន១៤០នាក់ ដែលក្នុងនោះមានមិត្តយុវជនជានិស្សិតមកពីប្រាំមហាវិទ្យាល័យក្នុងទីក្រុងភ្នំពេញ ដែលមានអាយុតិចជាង២០ឆ្នាំចំនួន២៥នាក់ស្មើនឹង១៧.៩% អាយុពី២០ដល់២៥ឆ្នាំចំនួន១១៣នាក់ស្មើនឹង៨០.៧% និងអាយុលើសពី២៥ឆ្នាំចំនួន២នាក់ស្មើនឹង១.៤% ដែលមានបង្ហាញនៅ**តារាងទី១**[23]។

| អាយុអ្នកឆ្លើយ | ប្រេកង់ | ភាគរយ |
|---|---|---|
| តិចជាង២០ឆ្នាំ | 25 | 17.9 |
| ពី២០ទៅ២៥ឆ្នាំ | 113 | 80.7 |
| លើសពី២៥ឆ្នាំ | 2 | 1.4 |
| សរុប | 140 | 100.0 |

**តារាងទី១ៈអាយុអ្នកឆ្លើយ**

#### ២.២.២.១. សមត្ថភាពយុវជនកម្ពុជា

ដោយផ្អែកលើទិន្នន័យ ដែលទទួលបានពីការធ្វើការស្ទង់មតិលើនិស្សិតចំនួន១៤០នាក់ ពី៥សាកលវិទ្យាល័យខ្ញុំឃើញថា ចំពោះការយល់ដឹងពីកម្រិតភាសាបរទេសយុវជនយើង ភាគច្រើនអាចប្រើប្រាស់បានច្រើនភាសាដែរ ដូចជាភាសាអង់គ្លេស បារាំង ចិន ជប៉ុន កូរ៉េ និងភាសាផ្សេងៗទៀត។ តាមទិន្នន័យដែលទទួលបាន និស្សិតដែលមានសមត្ថភាពនិយាយភាសាអង់គ្លេសបានល្អប្រសើរ មានន័យថាមានសមត្ថភាពប្រាស្រ័យទាក់ទងល្អជាភាសានេះ មានចំនួន៣.៦% និងកម្រិតជំនាញសសេរស្មើនឹង២.៩%នៃចំនួននិស្សិតសរុប។ រីឯ អ្នកដែលអាចប្រើប្រាស់បានល្អចំពោះការនិយាយមានចំនួន៣០.៧% និងអ្នកដែលអាចសសេរបានល្អស្មើ៣៥%។ ដោយឡែក ចំពោះនិស្សិតដែលយល់ដឹងជាបានល្អបង្គួរនូវភាសានេះមានចំនួន៤៥.៧%ចំពោះការនិយាយ និង៤២.១% ចំពោះជំនាញសសេរ ដែលនេះជាទិន្នន័យខ្ពស់ជាងគេក្នុងចំនោមលទ្ធផលដែលទទួលបាន។ ក្រៅពីនេះ និស្សិតដែលយល់ដឹងពីភាសានេះមាន កម្រិតតិចតួចនោះមានចំនួន១៧.១%ចំពោះការនិយាយ និងការសសេរចំនួន១៥%។

[23] លឹម ម៉ីលី, *ទិន្នន័យតាមរយៈការស្ទង់មតិ*, ភ្នំពេញ, ឧសភា ២០១៥។

បន្ថែមលើកម្រិតយល់ដឹងភាសាអង់គ្លេសបានតិចតួចនេះ ក៏មានយុវជនកម្ពុជាយើងខ្លះមិនបានសិក្សាពីភាសានេះផងដែរ ដោយមាន២.៩%ពួកគាត់មិនអាចនិយាយបាន និង៥%លើការសសេរជាភាសានេះ[24]។

**តារាងទី២៖កម្រិតនិយាយភាសាអង់គ្លេស**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អណាស់ | 5 | 3.6 |
| ល្អ | 43 | 30.7 |
| បង្គួរ | 64 | 45.7 |
| តិចតួច | 24 | 17.1 |
| អត់សោះ | 4 | 2.9 |
| សរុប | 140 | 100.0 |

**តារាងទី៣៖កម្រិតសរសេរភាសាអង់គ្លេស**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អណាស់ | 4 | 2.9 |
| ល្អ | 49 | 35.0 |
| បង្គួរ | 59 | 42.1 |
| តិចតួច | 21 | 15.0 |
| អត់សោះ | 7 | 5.0 |
| សរុប | 140 | 100.0 |

ក្រៅពីភាសាអង់គ្លេស យុវជនកម្ពុជាក៏អាចធ្វើការទំនាក់ទំនងជាភាសាបារាំងបានផងដែរ។ ដោយក្នុងនោះ មាននិស្សិត១.៤% អាចនិយាយបានល្អ និងការសរសេរវិញបានដល់២.១%។ ចំពោះការនិយាយនិងសរសេរបានល្អបង្គួរនូវភាសានេះមាន១០%ដូចគ្នា។ កម្រិតយល់ដឹង ឬប្រើប្រាស់បានតិចតួចមានចំនួន១៦.៤% ហើយការសរសេរមានចំនួនស្មើនឹង១២.៩%។ ផ្ទុយមកវិញ មានយុវជនយើង

[24] លឹម ម៉ីលី, *ទិន្នន័យតាមរយៈការស្ទង់មតិ*, ភ្នំពេញ, ឧសភា ២០១៥។

មួយចំនួនធំមិនបានសិក្សាពីភាសាបារាំងនេះមាន៧២.១%លើការនិយាយ និង៧៥%លើការសរសេរ។ នេះសរបញ្ជាក់ថា និស្សិតកម្ពុជាភាគច្រើនមិនសូវយកចិត្តទុកដាក់ចំពោះភាសាបារាំងឡើយ[25]។

**តារាងទី៤៖កម្រិតនិយាយភាសាបារាំង**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អ | 2 | 1.4 |
| បង្គួរ | 14 | 10.0 |
| តិចតួច | 23 | 16.4 |
| អត់សោះ | 101 | 72.1 |
| សរុប | 140 | 100.0 |

**តារាងទី៥៖កម្រិតសរសេរភាសាបារាំង**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អ | 3 | 2.1 |
| បង្គួរ | 14 | 10.0 |
| តិចតួច | 18 | 12.9 |
| អត់សោះ | 105 | 75.0 |
| សរុប | 140 | 100.0 |

ចំពោះភាសាចិនវិញ ដែលជាភាសាមួយពេញនិយម និងត្រូវបានប្រើប្រាស់ភាគច្រើនបន្ទាប់ពីភាសាអង់គ្លេសនៅក្នុងតំបន់អាស៊ីនេះ យុវជនកម្ពុជាក៏អាចនិយាយបានល្អប្រសើរផងដែរដោយមានចំនួន១.៤% និងសរសេរមាន០.៧%។ រីឯការនិយាយបានល្អវិញ យើងឃើញថាក៏នេះមានកម្រិតមួយទាបនៅឡើយដែរ គឺស្មើនឹង៥.៧% និងមានត្រឹមតែ៥%ប៉ុណ្ណោះដែលអាចសរសេរបាននោះ។ ចំពោះអ្នកដែលយល់ដឹងបង្គួរលើការនិយាយមាន៨.៦% និងសរសេរមានចំនួន១០% ចំណែកឯការចេះនិយាយបានតិចតួចនោះមាន២៥.៧% និងសរសេរមានត្រឹមតែ២១.៤%ទេ។ ច្រាសមកវិញយើងក៏

[25] លឹម ម៉ីលី, *ទិន្នន័យតាមរយៈការស្ទង់មតិ*, ភ្នំពេញ, ឧសភា ២០១៥។

ទទួលបានលទ្ធផលខ្ពស់ផងដែរចំពោះអ្នកដែលមិនចេះភាសានេះ ដោយមានរហូតដល់៥៨.៦%មិនចេះនិយាយ និង៦២.៩%មិនចេះសរសេរ[26]។

**តារាងទី៦៖កម្រិតនិយាយភាសាចិន**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អណាស់ | 2 | 1.4 |
| ល្អ | 8 | 5.7 |
| បង្គួរ | 12 | 8.6 |
| តិចតួច | 36 | 25.7 |
| អត់សោះ | 82 | 58.6 |
| សរុប | 140 | 100.0 |

**តារាងទី៧៖កម្រិតសរសេរភាសាចិន**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អណាស់ | 1 | 0.7 |
| ល្អ | 7 | 5.0 |
| បង្គួរ | 14 | 10.0 |
| តិចតួច | 30 | 21.4 |
| អត់សោះ | 88 | 62.9 |
| សរុប | 140 | 100.0 |

ភាសាបន្ទាប់បន្សំក្រៅពីភាសាខាងលើ យើងក៏មានអ្នកដែលអាចប្រើប្រាស់ភាសាជប៉ុនដែរ ដោយអ្នកដែលនិយាយបានល្អនៅមានកម្រិតទាប គឺមានតែ០.៧%ប៉ុណ្ណោះ។ អ្នកដែលនិយាយ និងសរសេរបានបង្គួរមានកម្រិតស្មើគ្នាគឺ២.៩%។ ប៉ុន្តែក្នុងចំនោមនិស្សិត១៤០នាក់នេះ ក៏នៅតែមានអ្នកចេះតិចតួចដែរ ដោយ៧.៩%អាចនិយាយបាន និងសរសេរមាន៧.១%។ នៅក្នុងការអង្កេតនេះ មានយុវជនយើង៨៨.៦%មិនចេះនិយាយ និង៩០%មិនអាចសរសេរភាសានេះបានទេ[27]។

[26] លឹម ម៉ីលី, *ទិន្នន័យតាមរយៈការស្ទង់មតិ*, ភ្នំពេញ, ឧសភា ២០១៥។

[27] លឹម ម៉ីលី, *ទិន្នន័យតាមរយៈការស្ទង់មតិ*, ភ្នំពេញ, ឧសភា ២០១៥។

**តារាងទី៨ ៖កម្រិតនិយាយភាសាជប៉ុន**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អ | 1 | 0.7 |
| បង្គួរ | 4 | 2.9 |
| តិចតួច | 11 | 7.9 |
| អត់សោះ | 124 | 88.6 |
| សរុប | 140 | 100.0 |

**តារាងទី៩៖កម្រិតសរសេរភាសាជប៉ុន**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អ | 0 | 0 |
| បង្គួរ | 4 | 2.9 |
| តិចតួច | 10 | 7.1 |
| អត់សោះ | 126 | 90 |
| សរុប | 140 | 100.0 |

ភាសាកូរ៉េ ក៏ជាភាសាមួយកំពុងពេញនិយមផងដែរនៅកម្ពុជាយើង។ ដោយឡែកនិស្សិតយើងដែលអាចនិយាយ និងសរសេរភាសាកូរ៉េបានល្អមានត្រឹមតែ0.៧%ដូចគ្នា រីឯការនិយាយ និងសរសេរបានល្អបង្គួរនោះក៏មានចំនួនដូចគ្នាផងដែរគឺស្មើនឹង១.៤%។ ការចេះដឹងតិចតួចវិញ គឺមាន១០%លើការនិយាយ និង៧.៩%ចំពោះការសរសេរ។ ម្យ៉ាងវិញទៀត អ្នកដែលមិនអាចនិយាយភាសានេះ មានដល់ទៅ៨៧.៩% និងការសរសេរមានរហូតដល់៩០%ឯនោះ[28]។

[28] លឹម ម៉ីលី, *ទិន្នន័យតាមរយៈការស្ទង់មតិ*, ភ្នំពេញ, ឧសភា ២០១៥។

**តារាងទី១០៖កម្រិតនិយាយភាសាកូរ៉េ**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អ | 1 | 0.7 |
| បង្គួរ | 2 | 1.4 |
| តិចតួច | 14 | 10.0 |
| អត់សោះ | 123 | 87.9 |
| សរុប | 140 | 100.0 |

**តារាងទី១១៖កម្រិតសរសេរភាសាកូរ៉េ**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អ | 1 | 0.7 |
| បង្គួរ | 2 | 1.4 |
| តិចតួច | 11 | 7.9 |
| អត់សោះ | 126 | 90.0 |
| សរុប | 140 | 100.0 |

និស្សិតកម្ពុជាយើង ក៏អាចធ្វើការទំនាក់ទំនងភាសាផ្សេងទៀតដែរក្រៅពីភាសាខាងលើ ដោយឃើញថា ពួកគាត់អាចនិយាយ និងសរសេរបានល្អប្រសើរនូវភាសាទាំងនោះគឺស្មើ០.៧%ដូចគ្នា ហើយ ២.១%អាចនិយាយបានល្អ និង២.៩%អាចសរសេរបានល្អ។ ចំពោះការនិយាយបានល្អបង្គួរមាន៩.៣% ហើយ៦.៤%នៃការសរសេរ។ ក្រៅពីនេះ កម្រិតយល់ដឹងតិចតួចលើការនិយាយមាន១៩.៣% និងសរសេរមានតែ១៤.៣%ប៉ុណ្ណោះ។ តែបើប្រៀបធៀបនឹងចំនួនយុវជនដែលក្រុមយើងខ្ញុំធ្វើការអង្កេតនេះ អ្នកដែលមិនចេះភាសាផ្សេងក្រៅពីភាសាខាងលើនោះ គឺមាន៦៨.៦%លើការនិយាយ និងរហូតដល់៧៥.៧%ចំពោះការសរសេរ[29]។

[29] លឹម ម៉ីលី, *ទិន្នន័យតាមរយៈការស្ទង់មតិ*, ភ្នំពេញ, ឧសភា ២០១៥។

**តារាងទី១២៖កម្រិតនិយាយភាសាផ្សេងៗ**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អណាស់ | 1 | 0.7 |
| ល្អ | 3 | 2.1 |
| បង្គួរ | 13 | 9.3 |
| តិចតួច | 27 | 19.3 |
| អត់សោះ | 96 | 68.6 |
| សរុប | 140 | 100.0 |

**តារាងទី១៣៖កម្រិតសរសេរភាសាផ្សេងៗ**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អណាស់ | 1 | 0.7 |
| ល្អ | 4 | 2.9 |
| បង្គួរ | 9 | 6.4 |
| តិចតួច | 20 | 14.3 |
| អត់សោះ | 106 | 75.7 |
| សរុប | 140 | 100.0 |

បើនិយាយពីកម្រិតសមត្ថភាពប្រើប្រាស់កម្មវិធីកុំព្យូទ័រ (Microsoft Office)វិញ យើងឃើញថាក្នុងចំនោមយុវជន១៤០នាក់ អ្នកដែលអាចប្រើប្រាស់កម្មវិធីនេះបានល្អប្រសើរនោះមានត្រឹមតែ៧.៩%ទេ រីឯអ្នកអាចប្រើបានល្អមានចំនួនគួរសមដែរគឺស្មើនឹង៣៥.៧%នៃចំនួនសរុប។ និស្សិតកម្ពុជា យើងសព្វថ្ងៃមានសមត្ថភាព ចំណេះដឹងលើបញ្ហាបច្ចេកវិទ្យាល្អបង្គួរ ពីព្រោះដោយផ្អែកលើទិន្នន័យដែលទទួលបានគឺមាន៤២.១% ហើយអ្នកដែលយល់ដឹងតិចតួចនោះក៏មានចំនួនតិចដែរគឺមានត្រឹមតែ១៤.៣%។ នេះបង្ហាញថា យុវជនកម្ពុជាមានសមត្ថភាពទទួលយកនូវរបកគំហើញថ្មី ការចង់ដឹងពីអ្វីដែលថ្មី ដូចជា

បច្ចេកទេសវិទ្យានេះជាដើម គឺមានន័យថាកម្ពុជាអាចដើរទាន់ប្រទេសអភិវឌ្ឍន៍មួយចំនួន ដែលមានការជឿនលឿននូវបញ្ហាបច្ចេកវិទ្យានេះ[30]។

**តារាងទី១៤៖កម្រិតសមត្ថភាពកុំព្យូទ័រ**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| ល្អណាស់ | 11 | 7.9 |
| ល្អ | 50 | 35.7 |
| បង្គួរ | 59 | 42.1 |
| តិចតួច | 20 | 14.3 |
| សរុប | 140 | 100.0 |

សម្រាប់ចំណេះដឹងដែលបានរៀបរាប់ខាងលើរបស់យុវជនយើង ដើម្បីត្រៀមខ្លួនសម្រាប់ការងារទៅថ្ងៃក្រោយ យើងឃើញថា អ្នកដែលមានសមត្ថភាពគ្រប់គ្រាន់មានត្រឹមតែ៦.៤%នៃចំនួនសរុប។ រីឯអ្នកដែលមានសមត្ថភាពល្មម សមរម្យនោះគឺមានចំនួន ២៩.៣% ហើយអ្នកដែលគិតថាខ្លួនមិនទាន់មានសមត្ថភាពគ្រប់គ្រាន់សម្រាប់អនាគតនោះមានរហូតដល់ ៦៣.៦%ឯនោះ ដែលបញ្ជាក់ថានិស្សិតកម្ពុជា មានផលពិបាកក្នុងការស្វែងរកការងារធ្វើទៅថ្ងៃក្រោយ ដោយសារតែគុណភាពអប់រំនៅមានកម្រិតនៅឡើយ[31]។

**តារាងទី១៥៖កម្រិតសមត្ថភាពការងារ**

| កម្រិត | ប្រេកង់ | ភាគរយ |
|---|---|---|
| គ្រប់គ្រាន់ណាស់ | 9 | 6.4 |
| សមល្មមហើយ | 41 | 29.3 |
| មិនគ្រប់គ្រាន់ | 89 | 63.6 |
| គ្មានយោបល់ | 1 | 0.7 |
| សរុប | 140 | 100.0 |

[30] លឹម ម៉ីលី, *ទិន្នន័យតាមរយៈការស្ទង់មតិ*, ភ្នំពេញ, ឧសភា ២០១៥។
[31] ដដែល។

### ២.២.២.២. ចំណេះដឹងយុវជននៅលើអាស៊ាន

ចំពោះចំណេះដឹងពីអាស៊ានវិញ ដូចជាអ្វីទៅជាគោលបំណងនៃការបង្កើតសមាគមអាស៊ាន នោះឃើញថា ក្រុមយុវជនមានអាយុតិចជាង២០ឆ្នាំមាន០.៧% ពួកគាត់គិតថាគេបង្កើតអាស៊ានក្នុងគោលបំណង ដើម្បីឱ្យប្រទេសជាសមាជិកមានការដឹកនាំផ្នែកនយោបាយដូចគ្នា ហើយក្នុងគោលបំណងដើម្បីសេដ្ឋកិច្ចដូចគ្នាមានចំនួន១២.៩% និងសម្រាប់អ្នកមិនមានយោបល់ក៏មាន៤.៣%ផងដែរនៅក្នុងក្រុមនេះ។ ចំពោះយុវជននៅក្នុងក្រុមពី២០ទៅ២៥ឆ្នាំវិញ នាងខ្ញុំសង្កេតឃើញថាកម្រិតយល់ដឹងពីគោលបំណងក្នុងការបង្កើតអាស៊ានមានចំនួនច្រើន បើប្រៀបធៀបនឹងក្រុមនិស្សិតដ៏ទៃទៀត ដោយមានដល់៦២.១% គឺជ្រើសរើសយកផ្នែកសេដ្ឋកិច្ច ៨.៦%ផ្នែកនយោបាយ និង១០%មិនមានគំនិតយោបល់លើសំនួរនេះ។

ចំពោះយុវជនដែលមានអាយុលើសពី២៥ឆ្នាំវិញ ឃើញថា 0.៧%យល់ថាដើម្បីផ្នែកសេដ្ឋកិច្ចដូចគ្នា និង0%គិតថានយោបាយដូចគ្នា ហើយគ្មានយោបល់សោះ 0%[32]។

**តារាងទី១៦៖ គោលបំណងនៃការបង្កើតអាស៊ាន**

| អាយុនៃនិស្សិត | | គោលបំណងនៃការបង្កើតអាស៊ាន | | | សរុប |
|---|---|---|---|---|---|
| | | នយោបាយ | សេដ្ឋកិច្ច | គ្មានយោបល់ | |
| តិចជាង២០ឆ្នាំ | ចំនួននិស្សិត | 1 | 18 | 6 | 25 |
| | ភាគរយ | 0.7% | 12.9% | 4.3% | 17.9% |
| ពី២០ទៅ២៥ឆ្នាំ | ចំនួននិស្សិត | 12 | 87 | 14 | 113 |
| | ភាគរយ | 8.6% | 62.1% | 10.0% | 80.7% |
| លើសពី២៥ឆ្នាំ | ចំនួននិស្សិត | 0 | 1 | 1 | 2 |
| | ភាគរយ | 0.0% | 0.7% | 0.7% | 1.4% |
| សរុប | ចំនួននិស្សិត | 13 | 106 | 21 | 140 |
| | ភាគរយ | 9.3% | 75.7% | 15.0% | 100.0% |

ចំណេះដឹងទាក់ទងនឹងបញ្ហាអាស៊ាននេះ ឃើញថាក្នុងចំនោមយុវជន១៤០នាក់ ហើយអ្នកដែលមានអាយុក្រោម២០ឆ្នាំនោះ មាន១៥%គឺពួកគាត់បានដឹងពីចំនួនសមាជិកអាស៊ានសរុប ថាតើសព្វថ្ងៃនេះអាស៊ានមានប្រទេសជាសមាជិកចំនួនប៉ុន្មាននោះគឺត្រឹមត្រូវច្រើន។ ចំណែកក្រុម ដែលមានអាយុចន្លោះពី២០ឆ្នាំទៅ២៥ឆ្នាំវិញទទួលបានអត្រាខ្ពស់គឺ ៥៨.៦%នៃចំនួនយុវជនសរុប។

[32] លឹម ម៉ីលី, *ទិន្នន័យតាមរយៈការស្ទង់មតិ*, ភ្នំពេញ, ឧសភា ២០១៥។

ដោយឡែក ក្រុមដែលមានអាយុលើសពី២៥ឆ្នាំវិញគឺ ឃើញថាការយល់ដឹងរបស់គាត់មានតិចតួចខ្លាំងណាស់ពីបញ្ហានេះ ដោយផ្អែកលើទិន្នន័យដែលទទួលបាន[33]។

**តារាងទី១៧៖ ចំនួនសមាជិកអាស៊ានតាមអាយុអ្នក**

| អាយុអ្នកឆ្លើយ | | ចំនួនសមាជិកអាស៊ាន | | | សរុប |
|---|---|---|---|---|---|
| | | 9 | 10 | 12 | |
| តិចជាង២០ឆ្នាំ | ចំនួននិស្សិត | 0 | 21 | 4 | 25 |
| | ភាគរយ | 0.0% | 15.0% | 2.9% | 17.9% |
| ពី២០ទៅ២៥ឆ្នាំ | ចំនួននិស្សិត | 4 | 82 | 27 | 113 |
| | ភាគរយ | 2.9% | 58.6% | 19.3% | 80.7% |
| លើសពី២៥ឆ្នាំ | ចំនួននិស្សិត | 0 | 0 | 2 | 2 |
| | ភាគរយ | 0.0% | 0.0% | 1.4% | 1.4% |
| សរុប | ចំនួននិស្សិត | 4 | 103 | 33 | 140 |
| | ភាគរយ | 2.9% | 73.6% | 23.6% | 100.0% |

បើនិយាយពីអាយុវិញ ក្រុមអ្នកដែលមានអាយុក្រោម២០ឆ្នាំដែលឆ្លើយត្រូវនូវសំនួរតើកម្ពុជាជាប្រទេសសមាជិកទីប៉ុន្មាននៅក្នុងអាស៊ានមាន១៣.៦%ដែលបានជ្រើសរើសយកសមាជិកទី១០ដែលជាចម្លើយត្រឹមត្រូវ រីឯក្រុមដែលមានអាយុពី២០ទៅ២៥ឆ្នាំធ្វើបានត្រូវមាចំនួន៥៩.៣% និងក្រុមអ្នកដែលលើសពី២៥ឆ្នាំមានត្រឹមតែ០.៧%ប៉ុណ្ណោះ។

[33] លឹម ម៉ីលី, *ទិន្នន័យតាមរយៈការស្ទង់មតិ*, ភ្នំពេញ, ឧសភា ២០១៥។

**តារាងទី១៨៖ សមាជិកភាពរបស់កម្ពុជាតាមអាយុ**

| អាយុអ្នកឆ្លើយ | | សមាជិកភាពរបស់កម្ពុជា | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ទី៥ | ទី៧ | ទី៩ | ទី១០ | ទី១១ | |
| តិចជាង២០ឆ្នាំ | ចំនួននិស្សិត | 0 | 1 | 5 | 19 | 0 | 25 |
| | ភាគរយ | 0.0% | 0.7% | 3.6% | 13.6% | 0.0% | 17.9% |
| ពី២០ទៅ២៥ឆ្នាំ | ចំនួននិស្សិត | 1 | 15 | 12 | 83 | 2 | 113 |
| | ភាគរយ | 0.7% | 10.7% | 8.6% | 59.3% | 1.4% | 80.7% |
| លើសពី២៥ឆ្នាំ | ចំនួននិស្សិត | 0 | 0 | 1 | 1 | 0 | 2 |
| | ភាគរយ | 0.0% | 0.0% | 0.7% | 0.7% | 0.0% | 1.4% |
| សរុប | ចំនួននិស្សិត | 1 | 16 | 18 | 103 | 2 | 140 |
| | ភាគរយ | 0.7% | 11.4% | 12.9% | 73.6% | 1.4% | 100.0% |

និយាយដល់បញ្ហាអាស៊ាន AFTA ដែលជាផ្នែកដ៏សំខាន់មួយនៅក្នុងសហាគមន៍សេដ្ឋកិច្ចអាស៊ាននោះ ត្រូវបានយុវជនកម្ពុជាយើងស្គាល់ដល់កម្រិតណា។ ដូចនេះនាងខ្ញុំ សូមបង្ហាញនូវទិន្នន័យដែលទទួលបានដូចតទៅ៖ ក្រុមអាយុក្រោម២០ឆ្នាំឆ្លើយត្រូវបាន៨.៦%ក្រុមចន្លោះពី២០ទៅ២៥ឆ្នាំមានចំនួន៥៦.៤%និងក្រុមលើសពី២៥ឆ្នាំមាន០.៧% នៃចំនួនសរុប១៤០នាក់នេះ[34]។

**តារាងទី១៩៖ AFTA ជាអ្វី? តាមអាយុ**

| អាយុអ្នកឆ្លើយ | | តើអ្វីទៅជា AFTA ? | | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | AFEA | AFTA | UN Agreement | WTO Agreement | Others | No option | |
| តិចជាង២០ឆ្នាំ | ចំនួននិស្សិត | 5 | 12 | 0 | 1 | 1 | 6 | 25 |
| | ភាគរយ | 3.6% | 8.6% | 0.0% | 0.7% | 0.7% | 4.3% | 17.9% |
| ពី២០ទៅ២៥ឆ្នាំ | ចំនួននិស្សិត | 9 | 79 | 3 | 6 | 0 | 16 | 113 |
| | ភាគរយ | 6.4% | 56.4% | 2.1% | 4.3% | 0.0% | 11.4% | 80.7% |
| លើសពី២៥ឆ្នាំ | ចំនួននិស្សិត | 0 | 1 | 0 | 1 | 0 | 0 | 2 |
| | ភាគរយ | 0.0% | 0.7% | 0.0% | 0.7% | 0.0% | 0.0% | 1.4% |

[34] លឹម ម៉ីលី, *ទិន្នន័យតាមរយៈការស្ទង់មតិ*, ភ្នំពេញ, ឧសភា ២០១៥។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| សរុប | ចំនួននិស្សិត | 14 | 92 | 3 | 8 | 1 | 22 | 140 |
| | ភាគរយ | 10.0% | 65.7% | 2.1% | 5.7% | 0.7% | 15.7% | 100.0% |

ដូចនេះយើងឃើញថា AFTA ត្រូវបានគេស្គាល់មិនច្រើនប៉ុន្មានទេ ដោយតួលេខដែលទទួលបាននេះគឺធ្វើលើនិស្សិតដែលទទួលបានការបណ្តុះបណ្តាលអប់រំ ចុះអ្នកដ៏ទៃដែលមិនមែនជាបញ្ញវ័ន្ត ឬក៏អ្នកសិក្សាវិញថាតើពួកគាត់យល់ដឹងបានកម្រិតណា។ ក្នុងន័យនេះសរបញ្ជាក់ឱ្យឃើញថា ប្រជាជនកម្ពុជាយើងមានចំនួនតិចតួចខ្លាំងណាស់ដែលយល់ដឹង ឬស្គាល់ ដឹងលឺពីបញ្ហាខាងក្រៅ ដូចជា បញ្ហាពិភពលោកវិបត្តិសេដ្ឋកិច្ចសាកល និងបញ្ហាផ្សេងៗទៀត។

ដូច្នោះ ពួកគាត់មិនទាន់បានត្រៀមខ្លួនគ្រប់គ្រាន់នៅឡើយទេ សម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចនាឆ្នាំ២០១៥ខាងមុខនេះ។ តើកម្ពុជាអាចប្រកួតប្រណាំងជាមួយគេបានកម្រិតណា បើគុណភាពអប់រំ ការសិក្សាយល់ដឹង កម្រិតភាសារបស់ប្រជាជននៅមានកម្រិតនៅឡើយ ជាពិសេសនោះគឺ យុវជន នៅពេលដែលមានលំហូរដោយសេរីនូវពលករជំនាញ ពីប្រទេសមួយទៅប្រទេសមួយ តើយុវជនកម្ពុជាទទួលតំណែងអ្វីនៅក្នុងអង្គភាព ក្រៅពីបុគ្គលិកតូចតាច ធ្វើការដែលគ្មានជំនាញ ឬជាកម្មករលីសែង។

### ២.២.២.៣. កម្រិតសមត្ថភាពយុវជនប្រកួតប្រជែងជាមួយយុវជនក្នុងតំបន់

យោងតាមការស្រង់មតិរបស់មិត្តនិស្សិតមក ឃើញថាការយល់ឃើញរបស់ពួកគេទៅលើសមត្ថ-ភាពផ្ទាល់ខ្លួនចំពោះការប្រកួតប្រជែងទៅថ្ងៃអនាគត ក្នុងនោះនិស្សិតអាយុក្រោម២០ឆ្នាំចំនួន២៥នាក់ មាន៦នាក់ យល់ថាខ្លួនមានសមត្ថភាពខ្ពស់សម្រាប់ប្រកួតប្រជែងជាមួយយុវជនដទៃក្នុងតំបន់ ១៥នាក់យល់ថាខ្លួនមានសមត្ថភាពមធ្យម ៣នាក់យល់ថាខ្លួនមានសមត្ថភាពខ្សោយ និង១នាក់គ្មានយោបល់។ និស្សិតអាយុចន្លោះ ពី២០ទៅ២៥ឆ្នាំចំនួន១១៣នាក់ មាន១៦នាក់យល់ថាខ្លួនមានសមត្ថភាពខ្ពស់សម្រាប់ប្រកួតប្រជែងជាមួយយុវជនដទៃក្នុងតំបន់ ៧៥នាក់យល់ថាខ្លួនមានសមត្ថភាពមធ្យម ១៣នាក់យល់ថាខ្លួនមានសមត្ថភាពខ្សោយ និង៩នាក់គ្មានយោបល់។ និស្សិតអាយុលើសពី ២៥ឆ្នាំចំនួន២នាក់ មាន១នាក់ យល់ថាខ្លួនមានសមត្ថភាពខ្ពស់សម្រាប់ប្រកួតប្រជែងជាមួយយុវជនដទៃក្នុងតំបន់ និង១នាក់ទៀតយល់ថាខ្លួនមានសមត្ថភាពមធ្យម[35]។

[35] លឹម ម៉ីលី, *ទិន្នន័យតាមរយៈការស្ទង់មតិ*, ភ្នំពេញ, ឧសភា ២០១៥។

**តារាងទី២០៖ សមត្ថភាពប្រកួតប្រជែងរបស់យុវជនខ្មែរតាមអាយុ**

| អាយុអ្នកឆ្លើយ | | សមត្ថភាពប្រកួតប្រជែងរបស់យុវជនខ្មែរ | | | | សរុប |
|---|---|---|---|---|---|---|
| | | ខ្ពស់ | មធ្យម | ខ្សោយ | គ្មានយោបល់ | |
| តិចជាង២០ឆ្នាំ | ចំនួននិស្សិត | 6 | 15 | 3 | 1 | 25 |
| | ភាគរយ | 4.3% | 10.7% | 2.1% | 0.7% | 17.9% |
| ពី២០ទៅ២៥ឆ្នាំ | ចំនួននិស្សិត | 16 | 75 | 13 | 9 | 113 |
| | ភាគរយ | 11.4% | 53.6% | 9.3% | 6.4% | 80.7% |
| លើសពី២៥ឆ្នាំ | ចំនួននិស្សិត | 1 | 1 | 0 | 0 | 2 |
| | ភាគរយ | 0.7% | 0.7% | 0.0% | 0.0% | 1.4% |
| សរុប | ចំនួននិស្សិត | 23 | 91 | 16 | 10 | 140 |
| | ភាគរយ | 16.4% | 65.0% | 11.4% | 7.1% | 100.0% |

សរុបមកមាននិស្សិតចំនួនតែ១៦.៤%=២៣នាក់ដែលយល់ថាខ្លួនមានសមត្ថភាពខ្ពស់សម្រាប់ប្រកួតប្រជែងជាមួយយុវជនដទៃក្នុងតំបន់ ដែលចំនួននេះសបញ្ជាក់ឲ្យឃើញថា សមត្ថភាពយុវជនខ្មែរនៅមានកម្រិតនៅឡើយ។ ហេតុនេះហើយ យុវជនកម្ពុជាត្រូវតែរៀបចំខ្លួន ពង្រឹងសមត្ថភាពគុណភាពសិក្សាដើម្បីសម្របខ្លួនសម្រាប់សមាហរណកម្មសេដ្ឋកិច្ចអាស៊ាននាពេលដ៏ខ្លីខាងមុខនេះ។

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១. បញ្ហាប្រឈម

ការចាប់ផ្ដើមនៃសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥ មានទាំងបញ្ហាប្រឈមមានទាំងឱកាសដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា។ ដើម្បីបន្តកំណត់ត្រាដ៏ល្អរបស់ខ្លួនក្នុងការធ្វើឲ្យសេដ្ឋកិច្ចលូតលាស់បង្កើតអោយមានការងារធ្វើសម្រាប់យុវជនប្រទេសកម្ពុជាត្រូវការទាក់ទាញ ហើយលើកទឹកចិត្តការវិនិយោគថ្មីៗទាំងការវិនិយោគក្នុងស្រុកទាំងការវិនិយោគពីបរទេស។ តាមរយៈក្របខ័ណ្ឌច្បាប់របស់ខ្លួនដែលមានការអនុគ្រោះសម្រាប់ក្រុមហ៊ុន អាជីវកម្ម ពាណិជ្ជកម្ម ប្រទេសកម្ពុជាបានទទួលជោគជ័យច្រើនក្នុងទសវត្សរ៍កន្លងទៅនេះ ដោយមានអត្រាលូតលាស់គិតជាមធ្យមជាង ៧%។ ទោះបីជាយ៉ាងណា បញ្ហាប្រឈម ក៏នៅតែជាក្ដីព្រួយបារម្ភរបស់កម្ពុជាក្នុងការចូលសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន។

ខណៈដែលយុវជនកម្ពុជា មានទទួលបានអត្ថប្រយោជន៍ ពីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន យុវជននៅតែមានបញ្ហាប្រឈម ក្នុងពេលអានាគត ដែលចាប់ផ្ដើមសមាហរណកម្មចុងឆ្នាំ២០១៥ នេះ។ យុវជនកម្ពុជាទូទាំងប្រទេសមានប្រមាណ៤លាននាក់ បើយោងតាមរបាយការណ៍ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ យុវជនកម្ពុជាប្រមាណ ១លាននាក់ បានធ្វើការចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស។ បញ្ហាប្រឈមចម្បងសម្រាប់ឆ្នាំខាងមុខនេះ គឺភាពខុសគ្នារវាងតម្រូវការទីផ្សារការងារ ជាពិសេសជំនាញសមត្ថភាពក្នុងការគិតពិចារណា ចំណេះដឹង ជាមួយនឹងទីផ្សារការងារនាពេលបច្ចុប្បន្ន។ ទីផ្សាររួមរបស់អាស៊ាន នឹងបើកទូលាយអោយមានចរន្តនៃកម្លាំងពលកម្មរបស់យុវជន ចូលគ្រប់បណ្ដានៃប្រទេសជាសមាជិក។ ទោះបីជាទីផ្សារបានបើកទូលាយ ប៉ុន្តែសមត្ថភាព ចំណេះដឹង ការយល់ដឹងពីអាស៊ាន ជំនាញ ភាសាបរទេស បច្ចេកវិទ្យា នៅមានកម្រិតដែលវាមិនទាន់សមស្របជាមួយបរិបទកម្ពុជា ដែលមានសេដ្ឋកិច្ចអន់ថយ និងកង្វះធនធានមនុស្ស។

### ៣.១.១. កង្វះការយល់ដឹងពីអាស៊ាន

#### ៣.១.១.១. កង្វះការតាមដានពត៌មាន

ជាទូទៅយុវជនខ្មែរមិនសូវចាប់អារម្មណ៍តាមដានព័ត៌មានទេ។ ព័ត៌មានតំបន់ ឬអន្តរជាតិរឹតតែនៅឆ្ងាយពីចំណាប់អារម្មណ៍របស់ខ្លួនថែមទៀត។ ភាពក្រីក្រ ការអប់រំនៅមានកម្រិត និងការ

រស់ជាប់ដៃតែបញ្ហាគ្រួសារ គឺជាហេតុផលមិនអាចប្រកែកបានដែលធ្វើឲ្យខ្មែរជាច្រើននៅឆ្ងាយពីបញ្ហាតំបន់និងពិភពលោក។

### ៣.១.១.២. ការផ្សព្វផ្សាយនូវមានកម្រិត

ការផ្សព្វផ្សាយពីបញ្ហាតំបន់នៅមានកម្រិត បណ្ដាញផ្សាយព័ត៌មានខ្មែរនិយាយតិចតួចណាស់អំពីអាស៊ាន ពីព្រោះសារព័ត៌មានភាគច្រើនសរសេរតែបញ្ហាសន្តិសុខសង្គម បញ្ហាគ្រោះថ្នាក់ចរាចរណ៍តែប៉ុណ្ណោះ។ ម្យ៉ាងទៀត រដ្ឋាភិបាលក៏មិនទាន់បានធ្វើកិច្ចការផ្នែកផ្សព្វផ្សាយព័ត៌មានអំពីអាស៊ានឲ្យបានគ្រប់គ្រាន់ទៅដល់មហាជនទូទៅ ជាពិសេសយុវជននៅឡើយ។

### ៣.១.១.៣. កង្វះឯកសារជាភាសាជាតិស្តីពីអាស៊ាន

កង្វះឯកសារជាសាភាជាតិស្ដីពីបញ្ហាអាស៊ានក៏ជាបញ្ហាធំផងមួយដែរ។ រាល់ឯកសារ នានាទាក់ទងនឹងកិច្ចការតំបន់ ដូចជា ចំណេះដឹងខាងសេដ្ឋកិច្ច នយោបាយ កិច្ចការទូត ជាដើមត្រូវបានសរសេរជាភាសាអង់គ្លេសដែលជាភាសាផ្លូវការរបស់អាស៊ាន។ នេះជាឧបសគ្គសម្រាប់ពលរដ្ឋខ្មែរក៏ដូចជា យុវជនជាច្រើនដែលមិនចេះភាសា។

## ៣.១.២. កង្វះធនធានមនុស្សដ៏ពូកែ

គុណភាពធនធានមនុស្ស គឺជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់ប្រទេសកម្ពុជា។ និស្សិតបញ្ចប់ការសិក្សាភាគច្រើនមិនត្រឹមតែនៅខ្សោយខាងចំណេះដឹង និងចំណេះធ្វើប៉ុណ្ណោះទេ តែពួកគេក៏ខ្សោយខាងការសរសេរ និងការជជែកពិភាក្សាទៀតផង។ អ្វីដែលយុវជន គួរតែយកចិត្តទុកដាក់ទៅលើគុណភាពនៃការសិក្សា មិនត្រូវឱ្យតម្លៃត្រឹមតែសញ្ញាបត្រមួយសន្លឹកនោះទេ។ នៅក្នុងកម្រិតឧត្តមសិក្សា និស្សិតដែលសិក្សាវិទ្យាសាស្ត្រសង្គម ដូចជាច្បាប់ និងសេដ្ឋកិច្ច មានចំនួនច្រើនរហូតដល់៥០ភាគរយ បើធៀបជាមួយនិស្សិតដែលសិក្សាផ្នែកបច្ចេកទេសមានចំនួនតែ ៤ភាគរយប៉ុណ្ណោះ។ យើងឃើញថាចំនួននេះ ពិតជាមានតិចតួចណាស់ ដែលធ្វើអោយមានការខ្វះខាតខ្លាំងក្នុងពេលសមាហរណកម្មចាប់ផ្តើម។[36] មានមូលហេតុជាច្រើនដែលបណ្ដាលឲ្យការបណ្ដុះបណ្ដាលធនធានមនុស្សនៅកម្ពុជាមិនសូវមានគុណភាព ដូចជា៖

[36] ហៃ ហ៊ុនឡេង, បទសម្ភាសដោយ កង កល្យាណ, *ទូរទស្សន៍ ស៊ី ធី អិន*, ២៥ មិថុនា ២០១៥។

**៣.១.២.១. ប្រព័ន្ធអប់រំនៅទន់ខ្សោយ**

មូលហេតុសំខាន់ជាងគេ ក្នុងការអភិវឌ្ឍន៍ធនធានមនុស្សឱ្យមានគុណភាព គឺប្រព័ន្ធអប់រំ។ នៅពេលដែលប្រពន្ធ័អប់រំដែលមិនអាចផ្តល់គ្រឹះរឹងមាំដល់សិស្ស នោះលទ្ធផលដែលទទួលបានមានតែផលអវិជ្ជមានប៉ុណ្ណោះ។ ទម្លាប់នៃការបង្រៀន និងការរៀនតាំងពីថ្នាក់ក្រោមនៅមិនអំណោយផលទាល់តែសោះដល់ការសរសេរ និងការជជែកវែកញែករបស់កុមារ និងយុវជន។ ជាទូទៅសិស្សអង្គុយចាំតែស្តាប់គ្រូ ចំណែកឯគ្រូវិញចូលចិត្តនិយាយឲ្យសិស្សស្តាប់ច្រើនជាងឲ្យសិស្សបង្កើតគំនិត ជជែកពិភាក្សាគ្នា និងសរសេរឲ្យបានច្រើន។[37] ទម្លាប់នេះបានធ្វើឲ្យសិស្សបាត់បង់ឱកាសក្នុងការសរសេរ ឬ ក្នុងការពិចារណា និងស្រាវជ្រាវដើម្បីបង្កើនធនធានបញ្ញារបស់ខ្លួន។ ចំណែកនៅថ្នាក់ឧត្តមសិក្សា ក៏នៅមានភាពធូរលុងនៅឡើយ សម្រាប់ការទទួលបានសញ្ញាបត្រ។ សរុបមក អ្នករៀនច្រើនប្រាថ្នាចង់បានសញ្ញាបត្រខ្ពស់ជាងចំណេះដឹង និងចំណេះធ្វើដែលវានៅតែជាចំណុចកម្សោយ។

ជាក់ស្តែង តាមទស្សនៈរបស់ **ខុង ជឺ** បាននិយាយថា ការអប់រំល្អ នាំឱ្យបុគ្គលមានគុណធម៌ នៅពេលដែលបុគ្គលមានគុណធម៌ នាំឱ្យសង្គមមានសណ្តាប់ធ្នាប់ ប្រទេសជាតិរីកចម្រើន ហើយគ្រួសារក៏មានសុភមង្គល។[38]

**៣.១.២.២. កង្វះអ្នកជំនាញវិជ្ជាជីវៈ**

នៅកម្ពុជា ទម្លាប់នៃការរៀនតាមគ្នាពីឪពុកទៅកូន និងពីជំនាន់មួយទៅមួយដោយមិនឆ្លងកាត់សាលាតាមរបៀបអ្វីដែលគេហៅថាចេះគ្មានក្បួន។ ជាការពិតគ្រួសារខ្មែរមានទម្លាប់ផ្ទេរចំណេះដឹងពីឪពុកទៅកូន ពីជីដូនទៅចៅ។ជាក់ស្តែង មុខរបរតម្បាញ ឬជាងទង និងជាងម៉ាស៊ីនជាដើម។

នៅក្នុងសម័យបច្ចេកវិទ្យាជឿនលឿន ដូចជាបច្ចុប្បន្ន ដែលទាមទារឲ្យមនុស្សមានជំនាញច្បាស់ និងប្រាកដប្រជានោះជំនាញដែលចេះតគ្នាមិនបានឆ្លងកាត់សាលា រឹតតែប្រឈមនឹងបញ្ហាខ្លាំងឡើងថែមទៀត។

ចំពោះនិស្សិតវិញ និស្សិតខ្លះពូកែខាងមុខវិជ្ជាវិទ្យាសាស្ត្រសង្គម បែរជាទៅរៀនជំនាញវិទ្យាសាស្ត្រពិត ហើយខ្លះទៀតពូកែខាងវិទ្យាសាស្ត្រពិតបែរ ជាទៅរៀនខាងវិជ្ជាសាស្ត្រសង្គមទៅវិញ។ ករណីខ្លះទៀត រៀនត្រូវជំនាញដែលខ្លួនមានហើយ តែបែរជាទៅធ្វើការខុសជំនាញវិញ។

---

[37] ប៉ែនបូណា,"កម្ពុជាខ្វះធនធានមនុស្សដ៏ពូកែ," *វិទ្យុបារាំងអន្តរជាតិជាខេមរភាសា*, ២០វិច្ឆិកា ២០១៤, http://km.rfi.fr /cambodia-lack-of-best-human-resource/(បានចូលមើលចុងក្រោយ ០១វិច្ឆិកា ២០១៨)។

[38] បណ្ឌិត ឈុន ណារ៉េត, *ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ* (ភ្នំពេញ៖ សុខ លាភ, ២០០៧), ១២៥។

#### ៣.១.២.៣. បទពិសោធន៍មានកម្រិត

ភាគច្រើននៃនិស្សិតកម្ពុជាបច្ចុប្បន្ន សិក្សាពីរវិទ្យាល័យ ឬអ្នកខ្លះទៀត បីវិទ្យាល័យក៏មាន ដែលធ្វើឱ្យពួកគេពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការក្រៅម៉ោងសម្រាប់ស្វែងរកបទពិសោធន៍ និងអភិវឌ្ឍជំនាញបន្ថែម។ ដូច្នេះ អ្វីដែលពួកគេអាចទទួលបាន គឺត្រឹមតែទ្រឹស្តីរៀននៅក្នុងសាលាតែប៉ុណ្ណោះ ចំនែកថាតើ ពួកគេអាចប្រើប្រាស់ទ្រឹស្តីទាំងនោះមកអនុវត្តក្នុងអនាគតការងារជាក់ស្តែងបានដល់កម្រិតណា មិនមានសេចក្តីប្រាកដនោះឡើយ។ ដូចនេះ វាជាឱកាសសម្រាប់និស្សិតបរទេសក្នុងការឆក់យកឱកាសការងារពីនិស្សិតខ្មែរនៅពេលសមាហរណកម្មចូលមកដល់។

### ៣.១.៣. កង្វះការត្រៀមខ្លួន

ការងារជំនាញជាច្រើន នឹងហូរចូលកម្ពុជាក្រោយពីសមាហរណកម្មអាស៊ាន ដែលវានឹងផ្តល់ការងារដ៏ច្រើនជូនយុវជនយើង ប៉ុន្តែយុវជនជាច្រើន មិនទាន់បានត្រៀមខ្លួនអោយបានរួចរាល់នៅឡើយទេ ជាមួយការមកដល់សមាហរណកម្មអាស៊ាន។

#### ៣.១.៣.១. ជំនាញរឹង និងជំនាញទន់

យុវជននៅកម្ពុជាមានចំនួនច្រើន ដែលសំបូរទៅដោយកម្លាំងពលកម្ម ប៉ុន្តែវិបត្តិធនធានមនុស្ស គឺជាបញ្ហាសម្រាប់កម្ពុជា ដែលទាមទារអោយកម្ពុជាមានការប្រកួតប្រជែងខ្លាំង។ កម្ពុជាមិនអាចធ្វើការដើរបានឡើយទាំងមុន និងក្រោយពេលចូលសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន។ តាមរយៈការសិក្សាស្រាវជ្រាវរបស់ធនាគារពិភពលោកឆ្នាំ២០១១ បង្ហាញថា៧៣ភាគរយ នៃនិយោជកត្អូញត្អែរថា និស្សិតដែលបានបញ្ចប់សាកលវិទ្យាល័យធ្វើការមិនត្រូវជំនាញដែលខ្លួនបានរៀន។ យុវជនខ្មែរជាច្រើន នៅមិនទាន់មានសមត្ថភាព មិនទាន់មានជំនាញ និងគ្មានលទ្ធភាពក្នុងការស្វែងរកការងារធ្វើ។ យុវជនកម្ពុជា ចំណេះដឹងនូវមានកម្រិតនៅឡើយ រួមទាំងភាសាបរទេស បើធៀបជាមួយប្រទេសជាសមាជិកម៉ាឡេស៊ី សឹង្ហបុរី ជាដើមពាក់ព័ន្ធបញ្ហាបច្ចេកវិទ្យា យុវជនកម្ពុជាក៏នៅមានកម្រិតទាប។

**ក្នុងរយៈពេលប្រាំឆ្នាំ ឬ ដប់ឆ្នាំ កម្ពុជាមានការចាញ់ប្រទេសដទៃ**
**ប៉ុន្តែក្នុងរយៈពេលវែងយើងខ្លាំងជាងគេ តាមរយៈការទទួលយកចំណេះដឹង**
**និងបទពិសោធពីប្រទេសដទៃ។**[39]

[39] កែម ឡី (អ្នកវិភាគ និងស្រាវជ្រាវសង្គម), បទសម្ភាសដោយ លឹម ម៉ីលី, ១៩ មិថុនា ២០១៥។

ជំនាញរឹង គឺជាជំនាញដែលយើងសិក្សានៅថ្នាក់ឧត្តមសិក្សា ឬ ថ្នាក់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស។ យុវជនខ្លួនឯងនៅមិនទាន់យល់ច្បាស់ ពីទីផ្សារការងារនៅអាស៊ានដែលធ្វើអោយពួកគេអាចទទួលបានការសិក្សាលើជំនាញដែលខ្លួនឯងពេញចិត្ត ឬជំនាញសាកសមនឹងសមត្ថភាពរបស់ខ្លួន។

ភាសាបរទេស ក៏ចាត់ទុកជាជំនាញមួយដែរដែលយុវជនមិនអាចមើលរំលងបាន។ វាគឺជាស្ពានចម្លងមួយរបស់ប្រទេសជាសមាជិកអាស៊ាន ប៉ុន្តែយុវជនកម្ពុជានៅហាក់បីដូចជាមើលរំលងដោយមិនទាន់បានពង្រឹងខ្លួនអោយបានប្រសើរជាមួយភាសាបរទេស។ ប្រទេសជាច្រើនបានចាប់យកភាសាអង់គ្លេសជាគោល ក្នុងការទំនាក់ទំនងគ្នាទៅវិញទៅមក ដែលជាតម្រូវការខ្ពស់នៅក្នុងអាស៊ានរវាង និយោជិត និងនិយោជក ក្នុងការបំពេញការងារ ឬការប្រាស្រ័យទាក់ទងគ្នារវាងយុវជន និងយុវជននៃបណ្តាប្រទេសអាស៊ាន។ យុវជនកម្ពុជានៅតែប្រឈមនឹងភាសាបរទេសខណៈដែលប្រទេសហ្វីលីពីន ម៉ាឡេស៊ី និងសឹង្ហបូរី បានប្រើប្រាស់ភាសាអង់គ្លេសយ៉ាងទូលំទូលាយ ក្នុងវិស័យពាណិជ្ជកម្មរបស់ខ្លួន។ កម្ពុជាត្រូវបានជាប់ចំណាត់ថ្នាក់ទី៦១ ក្នុងចំណោម៦៣ប្រទេស ដែលមានកម្រិតភាសាអង់គ្លេស ដែលបានជាប់ជាប្រទេសដែលមានជំនាញភាសាអង់គ្លេសកម្រិតមធ្យមក្នុងចំណោមមនុស្សពេញវ័យ។ កម្ពុជាត្រូវបានគេស្ទង់មតិប្រចាំឆ្នាំថាក្នុងចំណោមបណ្តាប្រទេសជាសមាជិក មានមធ្យមភាគទាបជាងគេ លើសមត្ថភាពភាសាអង់គ្លេស។ ប៉ុន្តែទិន្នន័យនេះត្រូវបានអ្នកស្រាវជ្រាវមួយចំនួន និងអ្នកជំនាញភាសាអង់គ្លេសបានបដិសេដ ពីព្រោះពួកគេបានពិនិត្យឃើញថាកម្រិតភាសាអង់គ្លេសនៅកម្ពុជាមានភាពល្អប្រសើរជាងប្រទេសវៀតណាម ថៃ និងឡាវ។[40] ភាសាអង់គ្លេស ត្រូវបានប្រើប្រាស់សម្រាប់ទំនាក់ទំនងគ្នាការស្វែងរកការងារ ការបម្រើការក្នុងសេវាកម្មណាមួយ វានឹងបង្កជាភាពពិបាកប្រសិនបើ មិនអាចនិយាយភាសាបរទេសបាន។ បើក្រឡេកមើលកម្រិតភាសាអង់គ្លេស របស់យុវជនក្នុងរាជធានីភ្នំពេញមានភាពប្រសើរច្រើន ប៉ុន្តែយុវជននៅតាមទីជនបទនៅតែមានកម្រិតទាប។ ដោយសារយុវជនយល់ឃើញថាកម្រិតនៃភាសា និងជំនាញនៃប្រទេសជាសមាជិកមានភាពខ្លាំងខ្លា និងពូកែធ្វើអោយពួកគេមានការភ័យខ្លាច ក្នុងការប្រកួតប្រជែងជាមួយយុវជនដទៃ។

ចំណែកឯជំនាញទន់ ក៏នៅមានការខ្វះខាតដែរសម្រាប់យុវជនកម្ពុជា។ ជំនាញទន់ ប្រែពាក្យពីភាសាអង់គ្លេសថា « Soft Skill » ជាជំនាញមួយបន្ថែមទៀតក្នុងការបំពេញការងារក្រៅពីជំនាញ

---

[40] មុនី សិទ្ធីណា, ជំនាញភាសាអង់គ្លេស ជាតម្រូវការក្នុងសមាហរណកម្មអាស៊ាន, *កាសែតខ្មែរថៃមស៍*, ៧ ឧសភា ឆ្នាំ២០១៥, http://www.khmertimeskh.com/news/11120/english-skills-in-demand-as-asean-integrates (បានចូលមើលចុងក្រោយ ៣០ ឧសភា ២០១៥)។

បច្ចេកទេស។ ជំនាញទន់ គឺផ្តោតលើការទំនាក់ទំនង ការងារជាក្រុម ការយល់ដឹងពីវប្បធម៌ ការដោះស្រាយបញ្ហា និងឥរិយាបទ។[41]

**ជំនាញទន់អាចធ្វើឱ្យបុគ្គលមានទំនុកចិត្តចំពោះខ្លួនឯង និងចេះលើកទឹកចិត្តខ្លួនឯងនៅក្នុងពេលបំពេញការងារ និងមានក្តីស្រមៃចង់ឱ្យខ្លួនមានសមត្ថភាពកាន់តែប្រសើរឡើងនៅក្នុងការងារ។**[42]

យុវជនកម្ពុជាជាច្រើន មានភាពខ្វះខាតយ៉ាងខ្លាំងលើជំនាញទាំងអស់នេះ ដោយសារពួកគេមិនសូវបានចូលរួមក្នុងសកម្មភាពសង្គម។ នៅពេលបញ្ចប់ថ្នាក់ឧត្តមសិក្សា យុវជនមួយចំនួនក៏មិនទាន់មានជំនាញទន់នេះគ្រប់គ្រាន់ផងដែរ។ ជារួមមក ជំនាញទន់ រាប់បញ្ចូលទាំងឥរិយាបថនៃការរស់ ឥរិយាបថក្នុងការបំពេញការងារ តាមរយៈការអភិវឌ្ឍន៍សមត្ថភាពក្នុងការគិតរបស់បុគ្គល។

### ៣.១.៣.២. កង្វះទំនុកចិត្តលើសមត្ថភាព និងការស្រាវជ្រាវ

យុវជនមួយចំនួនរបស់កម្ពុជា មានសមត្ថភាពខ្ពស់ក្នុងការប្រកួតប្រជែងជាមួយបណ្តាប្រទេសដទៃ ប៉ុន្តែយុវជនដែលមិនមានសមត្ថភាពច្បាស់លាស់ វាបានធ្វើអោយពួកគេមានការភ័យខ្លាចខ្វះការទុកចិត្តលើសមត្ថភាពខ្លួនឯងបានក្លាយជាឧបសគ្គមួយសម្រាប់យុវជនកម្ពុជា។ ប្រសិនបើយុវជនមានទំនុកចិត្ត និងជឿជាក់លើខ្លួនឯង យុវជនយើងនឹងមិនមានការព្រួយបារម្ភណាមួយកើតឡើងឡើយ នៅពេលប្រកួតប្រជែងជាមួយយុវជនប្រទេសដទៃ។ ម្យ៉ាងទៀត យុវជនកម្ពុជា នូវមានភាពខ្វះខាតនៅឡើយនៅការលើកទឹកចិត្តខ្លួនឯង ជម្រុញអោយមានការស្រាវជ្រាវ ការសិក្សាបន្ថែម និងការស្វែងរកចំណេះដឹង។ សម្រាប់យុវរជនកម្ពុជានាពេលបច្ចុប្បន្ន ពួកគេសិក្សាគ្រាន់តែចង់បានសញ្ញាបត្រដើម្បីមានការងារធ្វើតែប៉ុណ្ណោះ ពួកគេមិនបានខិតខំសិក្សាស្រាវជ្រាវដោយខ្លួនឯងដែលធ្វើអោយពួកគេមានការភ័យខ្លាច។ បញ្ហាទាំងអស់នេះហើយ ដែលយុវជនកម្ពុជាត្រូវប្រឈមនឹងកើតជំងឺធ្លាក់ទឹកចិត្ត ហើយមិនភាពក្លាហានប្រកួតប្រជែងជាមួយយុវជនដទៃ។

### ៣.១.៣.៣. ភាពភ័យខ្លាចកំណើននៃលំហូចូលកំលាំងពលកម្មជំនាញ

ប្រទេសកម្ពុជា មានភាពទាក់ទាញក្នុងការវិនិយោគពីវិនិយោគិនបរទេស។ កម្ពុជាមានភាពទាក់ទាញយកផលប្រយោជន៍បានច្រើនពីសមាហរណកម្មអាស៊ាន ប៉ុន្តែយុវជននៅមានការភ័យខ្លាចអំពីលំហូរចូល ច្រើនជាងលំហូរចេញ។ កម្ពុជាមានកម្លាំងកម្មករច្រើន ដែលសុទ្ធសឹងជាកម្លាំងយុវជន ប៉ុន្តែពួកគេជាកម្មករអត់ជំនាញ ហើយទទួលបានតម្លៃកម្លាំងពលកម្មទាប។

---

[41] ហៃ ហ៊ុនឡេង, បទសម្ភាសដោយ កង កល្យាណ, *ទូរទស្សន៍ ស៊ី ធី អិន*, ២៥ មិថុនា ២០១៥។

[42] ប៉ែន បុប្ផា, បទសម្ភាសដោយ ម៉ៅ សំណាង, *សារព័ត៌មានថ្មីៗ*, ០២ កក្កដា ២០១៥។

ចំណែកឯការងារជំនាញវិញ កម្ពុជាអាចប្រឈមមុខនឹងលំហូរនៃពលករជំនាញ មកពីប្រទេសដែលជាសមាជិកអាស៊ាន ហើយដែលយុវជនខ្មែរពិបាកក្នុងការប្រកួតប្រជែង។ ការយល់ឃើញបែបនេះហើយដែលធ្វើអោយយុវជនយើង មានភាពភ័យខ្លាច មិនហ៊ានប្រកួតប្រជែងជាមួយយុវជនប្រទេសជាសមាជិក វាបានបង្ហាញពីឱកាសនៃការបាត់បង់ការងារសម្រាប់យុវជនកម្ពុជា។

**ពួកគេច្រើនតែងគិតក្នុងន័យអវិជ្ជមានចំពោះខ្លួនឯង និងខ្លាចអោជានិច្ចចំពោះការប្រកួតប្រជែងដណ្តើមយកឱកាសការងារ។**[43]

បញ្ហានេះបានបង្អាក់ដល់ការត្រៀមខ្លួនរបស់យុវជនក្នុងសមាហរណកម្មអាស៊ាន ពីព្រោះពួកគេបានយល់ថាសមត្ថភាពយុវជននៃសមាជិកបណ្តាប្រទេសអាស៊ាន នឹងអាចដណ្តើមបានទីផ្សារការងារនៅកម្ពុជា។

## ៣.២. វិធានការដោះស្រាយ

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ គឺជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេសទាំងក្នុងពេលចំពោះមុខ ទាំងសម្រាប់អនាគត ពិសេសក្នុងពេលដែលកម្ពុជាឈានចូលទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងពេលដ៏ខ្លីខាងមុខហើយបន្តឡើង ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ ២០៥០។[44] ក្នុងន័យនេះ ការអភិវឌ្ឍធនធានមនុស្សជាពិសេសយុវជន គឺសំដៅទៅលើការកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើ សហគ្រិនភាព ជំនាញ ការច្នៃប្រឌិត និងនវានុវត្តន៍គ្រប់ផ្នែក គ្រប់វិស័យ ពិសេសផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស ព្រមទាំងសមត្ថភាពក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍ។

ហេតុនេះ ដើម្បីឲ្យការអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធិភាព និងគុណភាពដើម្បីបោះជំហ៊ានចូលសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន នាពេលដ៏ខ្លីខាងមុខនេះ ប្រាកដណាស់ថាត្រូវតែមានការចូលរួមជ្រោមជ្រែងរៀបចំពីសំណាក់រាជរដ្ឋាភិបាល ហើយពិសេសជាងនេះទៅទៀត គឺយុវជនខ្លួនឯងផ្ទាល់ ត្រូវតែមានស្មារតីប្រឹងប្រែងតស៊ូដើម្បីប្រកួតប្រជែងជាមួយនឹងធនធានមនុស្សដទៃទៀតក្នុងតំបន់។

---

[43] ប៉ែន បុប្ផា, បទសម្ភាសដោយ មៅ សំណាង, *សារព័ត៌មានថ្មីៗ*, ០២ កក្កដា ២០១៥។

[44] យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣, កញ្ញា ២០១៣។

### ៣.២.១. រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើយុវជន ដែលជាសសរទ្រូងនៃប្រទេសជាតិដោយផ្តល់ការសិក្សាប្រកបដោយគុណភាព និងមានសមត្ថភាពអាចឈានអាចឈានចូលក្នុងទីផ្សារការងារដោយងាយស្រួល។ ក្នុងនោះ ក៏នៅមានយុវជនមួយចំនួនពុំទាន់មានឱកាសទទួលបានការងារសមស្របនៅឡើយ។ រីឯយុវជនមួយចំនួនក៏បានធ្វើចំណាកស្រុកទៅកាន់ប្រទេសនានាដើម្បីស្វែងរកឱកាសរកប្រាក់ចំណូល[45]។

ដើម្បីអភិវឌ្ឍសមត្ថភាពយុវជន និងលើកកម្ពស់សិទ្ធិ និងការទទួលខុសត្រូវរបស់យុវជនដែលជាកម្លាំងសកម្មរបស់ប្រទេសជាតិរាជរដ្ឋាភិបាលកម្ពុជាបានកំណត់ថា មានតែការអប់រំទេដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចមួយប្រកបដោយចីរភាពឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ ហើយដើម្បីឲ្យយុវជនមានសមត្ថភាពជំនាញគ្រប់គ្រាន់ឆ្លើយតបទៅនឹងសេចក្តីត្រូវការទីផ្សារពលកម្ម និងបង្កើនឲ្យកាសទទួលបានការងារ ។

បន្ថែមលើនេះទៅទៀត រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ នៅក្នុងចតុកោណទី៤ សម្រាប់ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្សដែលមានដូចជា (១) ការលើកកម្ពស់ការយលដឹង និងសមត្ថភាពធនធានមនុស្ស ក្នុងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈវិធានការគន្លឹះមួយចំនួន ជាអាទិ៍ ការបញ្ជ្រាបការយល់ដឹង និងផលប្រយោជន៍អំពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត។ (២)បង្កើនលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ និងពង្រឹងគុណភាព ប្រសិទ្ធិភាពនៃសេវាអប់រំគ្រប់កម្រិតសិក្សា ក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងមុខជំនាញ ទាំងក្នុងគ្រឹះស្ថានរដ្ឋ និងឯកជនឲ្យស្របតាមកម្រិតស្តង់ដារអន្តរជាតិ និងតម្រូវការអភិវឌ្ឍប្រទេស។ (៣)ការជំរុញរៀបចំ និងអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសំដៅលើកកម្ពស់ផលិតភាពការងារ ដោះស្រាយ និងកាត់បន្ថយភាពគ្មានការងារធ្វើរបស់យុវជន ព្រមទាំងបង្កើនចំណូលរបស់ប្រជាជន និងធានាសមធម៌។

ដើម្បីឆ្លើយតបទៅនឹងសមាហរណកម្មអាស៊ាន រាជរដ្ឋាភិបាល តាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានខិតខំធ្វើកំណែទម្រង់វិស័យអប់រំ និងដាក់ចេញនូវវិធានការសំខាន់ៗជាអាទិ៍៖ (១)ធ្វើទំនើបកម្មកម្មវិធីសិក្សា ដូចជា (ក) ការរៀបចំកែលម្អកម្មវិធីសិក្សា ចាប់ពីកម្រិតបឋម ដល់ថ្នាក់ទី១២ (ខ) បញ្ចូលភាសាអង់គ្លេស ២ម៉ោងក្នុងមួយសប្តាហ៍ ចាប់ពីថ្នាក់ទី៤ (គ) ជម្រុញឧត្តមសិក្សាឲ្យបង្កើនសកម្មភាពស្រាវជ្រាវ។ (២) ចុះពិនិត្យស្ថានភាពជាក់ស្តែងគ្រឹះស្ថានឧត្តមសិក្សាទាំង១១

[45] គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា, ២៤ មិថុនា ២០១១។

ដែលមាន សាកលវិទ្យាល័យរដ្ឋ៦ និងឯកជន៥ ចាប់ពី ខែ កក្កដា ឆ្នាំ២០១៥នេះ ដោយឈរលើស្តង់ដាវាយតម្លៃគុណភាពអប់រំ ហើយឆ្នាំ២០១៦ ក្រសួងនឹងចុះពិនិត្យគ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេស។ (៣) នាយកដ្ឋានអាស៊ានរបស់ក្រសួងអប់រំ កំពុងរៀបចំបញ្ចូលការសិក្សាពីអាស៊ានចាប់ពីថ្នាក់ទី៩។ (៤) ជម្រុញឱ្យសាលាទាំងអស់នូវគ្រប់កម្រិតបង្កើន Soft Skill (ជំនាញទុន) និង Learning Exchange Program (កម្មវិធីបំលាស់ប្តូរការសិក្សា) ដល់សិស្សនិស្សិតមានជំនាញក្នុងកិច្ចទំនាក់ទំនង ដើម្បីឲ្យ យុវជនសម្លឹងមើល ពីរបៀបធ្វើទំនាក់ទំនង ភាពក្លាហាន បង្កើនកម្រិតភាសាតាមរយៈការចូលរួម ដំណើរទស្សនកិច្ចសិក្សាជាមួយនិស្សិតបរទេស[46]។

ទាំងនេះសុទ្ធសឹងតែជាការចូលរួមចំណែករបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍធនធានយុវជនកម្ពុជា ដើម្បីផ្តល់ឱកាសឲ្យយុវជនគ្រប់រូបអភិវឌ្ឍសមត្ថភាពប្រកបដោយឆន្ទៈ សេចក្តីព្យាយាមក្នុងស្មារតីប្រកួតប្រជែង និងមនសិការវិជ្ជាជីវៈ។

### ៣.២.២. ការត្រៀមខ្លួនរបស់យុវជន

សមាហរណកម្មអាស៊ាន បាននឹងខិតជិតមកដល់ហើយ ដែលយុវជនទាំងអស់ត្រូវត្រៀមខ្លួនដើម្បីស្វាគមន៍បើកការទទួលយកនូវបរិបទថ្មីនៃទីផ្សាររួមរបស់អាស៊ីអាគ្នេយ៍។ លោក កែម ឡី អ្នកវិភាគសង្គមបានគូសបញ្ជាក់ថា យុវជនកម្ពុជាដើរតួនាទីសំខាន់ណាស់ ក្នុងការកសាងសហគមន៍អាស៊ានទាំងនៅក្នុងដំណាក់កាលបច្ចុប្បន្ន និងទៅអនាគត ហើយវាជាសញ្ញាណល្អសម្រាប់យុវជនកម្ពុជាផងដែរ។ ដើម្បីអោយយុវជនមានការប្រកួតប្រជែងបានល្អ យុវជនគួរតែត្រៀមប្រាំចំណុចសម្រាប់ទីផ្សារការងារក្នុងសមាហរណកម្មអាស៊ាននាពេលខាងមុខ។ ទីមួយ៖ យុវជនកម្ពុជាត្រូវរៀនសិក្សាពីអន្តរវប្បធម៌ នៃបណ្តាប្រទេសជាសមាជិក។ ទីពីរ៖ យុវជនកម្ពុជាត្រូវប្រឹងប្រែងលើភាសាបរទេស ពីព្រោះយុវជនកម្ពុជាមានភាពយឺតយ៉ាវផ្នែកភាសាបរទេស។ ទី៣៖ បច្ចេកវិទ្យា ដែលបានវិវឌ្ឍពីមួយថ្ងៃទៅមួយកាន់តែរីកចម្រើនជាងមុន ដែលយុវជនត្រូវតាមអោយទាន់ជាមួយបច្ចេកវិទ្យា។ ទីបួន៖ ស្វែងរកសាលាដែលមានស្តង់ដាគុណភាពអប់រំ ដែលមានការទទួលស្គាល់ច្បាស់លាស់ ប្រសិនបើរៀនសូត្រនៅសាលាដែលមិនមានស្តង់ដា ទោះបីជាមានសញ្ញាបត្រខ្ពស់ក៏មិនអាចប្រកួតប្រជែងជាមួយអ្នកយុវជនដទៃដែរ។ ទីប្រាំ៖ ការផ្តោតលើជំនាញឯកទេស ដែលត្រូវផ្តោតតាំងពីវិទ្យាល័យ ដើម្បីអោយមានជំនាញឯកទេសច្បាស់លាស់[47]។

[46] រស់ សាលីន (នាយកខុទ្ទកាល័យ និងជាអ្នកនាំពាក្យនៃក្រសួងអប់រំ យុវជន និងកីឡា), បទសម្ភាសដោយ លឹម ម៉ីលី, ០៨ មិថុនា ២០១៥។

[47] បណ្ឌិត កែម ឡី, បទសម្ភាសដោយ លឹម ម៉ីលី, ១៩ មិថុនា ២០១៥។

យុវជនកម្ពុជាក៏ត្រូវបានជំរុញឲ្យបង្កើនការយល់ដឹងពីវប្បធម៌ឲ្យបានទូលំទូលាយ។ អាស៊ានជាបណ្តុំប្រទេសចំនួន១០ដែលក្រៅតែពីមានភាសាខុសគ្នា ហើយវប្បធម៌ក៏ខុសប្លែកពីគ្នាខ្លាំងណាស់ដែរ។ ការយល់ដឹងពីវប្បធម៌ឲ្យបានទូលំទូលាយជាពិសេសវប្បធម៌របស់ប្រទេសដែលជាគោលដៅបំពេញការងារនឹងជួយឲ្យយុវជនបានច្រើន ទាំងនៅក្នុងការងារ និងការប្រាស្រ័យទាក់ទង។ ថ្វីត្បិតតែការរៀបចំត្រៀមខ្លួននៅពេលនេះហាក់ដូចជាយឺតពេលបន្តិច ក៏ប៉ុន្តែប្រសិនបើអាចសម្រេចបានមែននោះ យុវជនកម្ពុជាយើងនឹងអាចទាញយកផលប្រយោជន៍បានយ៉ាងច្រើនពីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននាពេលខាងមុខនេះ។ សមាហរណកម្មសេដ្ឋកិច្ចអាស៊ានដែលនឹងខិតជិតចូលមកដល់នៅពេលដ៏ខ្លីខាងមុខនេះ។ ជាងនេះទៅទៀត ដើម្បីជោគជ័យដើម្បីការអភិវឌ្ឍ យុវជនអាស៊ាន ជាពិសេសយុវជនកម្ពុជាចាំបាច់ត្រូវបង្កើនការទាក់ទងល្អជាមួយប្រទេសជិតខាងនិងប្រទេសក្នុងតំបន់ និងជាពិសេស គឺត្រូវពង្រឹងសមត្ថភាពព្រមទាំងជំនាញរបស់ខ្លួនឲ្យបានខ្លាំងខ្លា។ ក្នុងបរិបទដែលយុវជនកម្ពុជាប្រឈមនឹងបញ្ហាខ្វះជំនាញ និងចំណេះដឹងយុវជនខ្មែរគួរត្រៀមខ្លួនគួរតែត្រៀមពីរចំនុចសំខាន់ គឺភាសាបរទេស និងជំនាញ ដើម្បីជ្រែកទីផ្សារការងារពេលអាស៊ានប្រែក្លាយខ្លួនជាសហគមន៍តែមួយ។[48]

**ទីមួយ** ដំបូងបង្អស់គឺចំណេះដឹងផ្នែកភាសា។ កន្លងមកនិន្នាការនៃការជ្រើសរើសរៀនភាសារបស់យុវជននៅកម្ពុជាប្រែប្រួលទៅតាមស្ថានភាពទីផ្សារការងារ។ តាំងពីដើមមកហើយយុវជនខ្មែរផ្តល់តម្លៃខ្លាំងទៅលើការសិក្សាភាសាអង់គ្លេស និងចិនដោយសារតែងាយរកការងារធ្វើ និងងាយទទួលបានប្រាក់ខែខ្ពស់។ប៉ុន្តែក្រោយមក ដោយសារតែមានអ្នកវិនិយោគកូរ៉េចូលមករកស៊ីនៅកម្ពុជាច្រើនយុវជនខ្មែរក៏បានងាកទៅរៀនភាសាកូរ៉េវិញ។ ភាពពេញនិយមរបស់ភាសាកូរ៉េបានថយចុះនាពេលបន្ទាប់មកជំនួសមកវិញដោយភាសាជប៉ុនក្រោយពីវត្តមានកុះកររបស់ក្រុមហ៊ុនជប៉ុននៅកម្ពុជា។ អ្នកជំនាញ បានលើកទឹកចិត្តចំពោះចំណង់រៀនភាសាបរទេសរបស់យុវជនកម្ពុជា ប៉ុន្តែបានណែនាំឲ្យខិតខំប្រឹងប្រែងបន្ថែមទៀតចំពោះភាសាអង់គ្លេស ដែលជាភាសាការងារផ្លូវការរបស់អាស៊ាន។ ទន្ទឹមគ្នានេះយុវជនខ្មែរក៏ត្រូវបានលើកទឹកចិត្តឲ្យសិក្សាភាសាមួយបន្ថែមទៀត។ ភាសាមួយណាក៏បាន នៃប្រទេសជាសមាជិកអាស៊ានទាំងដប់។ចំណេះដឹងភាសាអង់គ្លេស នឹងជួយអោយយុវជនយើងអាចរក្សាការងារ និងតួនាទីរបស់ខ្លួនបាន ការមិនមានចំណេះដឹងលើភាសាបរទេសនេះវានឹងធ្វើអោយពួកគេទទួលបានការងារដោយប្រើកំលាំង ហើយយុវជនគួរតែរៀនភាសាផ្សេង

[48] អ៊ឹម រចនា, យុវជនខ្មែរត្រូវត្រៀមខ្លួនជ្រែកទីផ្សារការងារ ពេលអាស៊ានប្រែខ្លួនជាសហគមន៍តែមួយ, *វិទ្យុបារាំងអន្តរជាតិ ជាខេមរភាសា*, ៣ មិថុនា ២០១៥ ,http://km.rfi.fr/cambodia/khmer-youth-labor-ready-interference-asean-substantially-same-community-03-06-2015 (បានចូលមើលចុងក្រោយ ០៤មិថុនា ២០១៥)។

បន្ថែមទៀត ក្រៅពីភាសាអង់គ្លេស[49]។ តាមការពិសោធរបស់អ្នកមានបទពិសោធផ្នែកការងារ បានបញ្ជាក់ថាយុវជនគួរចេះប្រាំភាសាអោយបានច្បាស់លាស់ គឺភាសាខ្មែរ ភាសាសកល (ភាសាអង់គ្លេស ចិន ឬ ភាសាផ្សេងទៀត) ភាសាបច្ចេកវិទ្យា ភាសាការទូត និងភាសាអាជីព។[50]

**ទីពីរ** សំខាន់បំផុតគឺជំនាញវិជ្ជាជីវៈ និងជំនាញទន់។ ដូចបានលើកឡើងមុននេះហើយថា នៅពេលអាស៊ានធ្វើសមាហរណកម្មទីផ្សារការងារលែងមានព្រំដែនទៀតហើយ។ យុវជនមកពីគ្រប់ប្រទេសនៅក្នុងអាស៊ានមានឱកាសស្មើៗគ្នា ក្នុងការដណ្តើមយកការងារល្អៗ។ យុវជនត្រូវរៀនជំនាញដែលខ្លួនពេញចិត្ត ហើយស្របជាមួយទីផ្សារការងារ។ យុវជនដែលបានជ្រើសរើសជំនាញដែលខ្លួនពេញចិត្តធ្វើអោយយុវជនមានភាពវិវឌ្ឍន៍លឿន ក្នុងការយល់ដឹងពីជំនាញរបស់ខ្លួន។ នៅពេលមានជំនាញហើយ ត្រូវមានជំនាញទន់រួមមានទំនាក់ទំនង ការយល់ដឹងពីវប្បធម៌នៃបណ្តាប្រទេសសមាជិក និងជាចំណេះដឹងពាក់ព័ន្ធនឹងឥរិយាបទ។ ឥរិយាបទធ្វើការរបស់មនុស្សម្នាក់ៗនឹងជំរុញអោយមានយុវជនមានឱកាសច្រើនក្នុងការងារ ដែលយុវជន មិនអាចមើលរំលងបាននូវជំនាញនេះ។ យុវជនត្រូវចាប់ជំនាញនេះចាប់តាំងពីកម្រិតថ្នាក់មធ្យមសិក្សា តាមរយៈការចូលរួមជាមួយក្នុងសកម្មភាពសង្គម។ យុវជន ត្រូវជម្នះរាល់ឧបសគ្គ ហើយត្រូវខិតខំហ្វឹកហាត់ខ្លួន កសាងសមត្ថភាពទាំងជំនាញវិជ្ជាជីវៈ ជំនាញទន់របស់ខ្លួនឱ្យមានគុណភាព ជាពិសេសយុវជនរក្សាឱ្យបាននូវអត្តចរិតត្រឹមត្រូវថ្លៃថ្នូរ មានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញការងារ។ ការបង្កើនគុណភាពនៃជំនាញទន់ វាក៏អាស្រ័យទៅលើ យុវជនម្នាក់ៗ ព្រោះយុវជនអាចស្វែងរកជំនាញនេះបានគ្រប់ទីកន្លែង ដោយចាប់ផ្តើមរៀនសង្កេត រៀនពិនិត្យ រៀនធ្វើទំនាក់ទំនងជាមួយមនុស្សជុំវិញខ្លួន រៀនពីមនុស្សជុំវិញខ្លួនឱ្យបានច្រើន ត្រូវមានចំណេះដឹងទូទៅទូលំទូលាយ ដើរឱ្យទាន់សម័យបច្ចេកវិទ្យា ប្រសិនបើបុគ្គលនោះមិនមានសមត្ថភាពពីធម្មជាតិ។[51]

---

49 មុនី សិទ្ធីណា, ជំនាញភាសាអង់គ្លេស ជាតម្រូវការក្នុងសមាហរណកម្មអាស៊ាន, *កាសែតខ្មែរថែមស៍*, ៧ ឧសភា ឆ្នាំ២០១៥, http://www.khmertimeskh.com/news/11120/english-skills-in-demand-as-asean-integrates (បានចូលមើលចុងក្រោយ ៣០ ឧសភា ២០១៥)។

50 ដោ៉ល គាន, បទសម្ភាសដោយកង កល្យាណ, *ទូរទស្សន៍ ស៊ី ធី អិន*, ២៥ មិថុនា ២០១៥។

51 ប៉ែន បុប្ផា, បទសម្ភាសដោយ មៅ សំណាង, *សារព័ត៌មានថ្មីៗ*, ០២ កក្កដា ២០១៥។

# សេចក្តីសន្និដ្ឋាន

សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) គឺជាមូលដ្ឋានគ្រឹះមួយនៅក្នុងចំនោមមូលដ្ឋានគ្រឹះ នានា ហើយការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ក៏ដូចជាការបង្កើតទីផ្សាររួមមួយ ដែលមានប្រជាពលរដ្ឋជាង ៦០០ លាននាក់ នឹងផ្តល់ឲ្យកម្ពុជាទាំងផលប្រយោជន៍ និងកត្តាប្រឈមជាច្រើនទៅដល់យុវជនដែលតម្រូវឲ្យកម្ពុជាត្រូវតែដោះស្រាយនូវបញ្ហាប្រឈមទាំងឡាយណាដែលកើតមានឡើង។ ប៉ុន្តែទោះបីជាមានការលំបាក និងឧបសគ្គយ៉ាងណាក៏ដោយ ក៏បច្ចុប្បន្ននេះ កម្ពុជាមិនថារាជរដ្ឋាភិបាល និងយុវជនខ្លួនឯងផ្ទាល់ បានខិតខំដោះស្រាយតាមរយៈការប្រឹងប្រែងតាំងពីពេលចាប់ផ្តើម មកដល់សព្វថ្ងៃ និងគម្រោងទៅអនាគត។ ម៉្យាងទៀតដោយសារតែសេដ្ឋកិច្ចជាតិមិនទាន់រឹងមាំគ្រប់គ្រាន់ ប្រទេសកម្ពុជាពិតមិនអាចឈរតែឯងក្នុងទីផ្សារអន្តរជាតិបានទេ។ ដូចនេះ សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់នាំមកឲ្យកម្ពុជាបានចូលទៅក្នុងទីផ្សាររួមដែលមានការប្រកួតប្រជែងខ្លាំង ហើយវាជាកត្តាជម្រុញមួយសម្រាប់ឲ្យប្រទេសនេះក៏ដូចជាប្រជាជន ពិសេសយុវជនឈានទៅកាន់ការអភិវឌ្ឍដ៏ប្រសើរ។

រីឯលទ្ធផលនៃការវាស់ស្ទង់មតិមិត្តនិស្សិតវិញ នាងខ្ញុំឃើញថាពួកគេនៅមានចំនុចខ្វះខាតជាច្រើនទាំងចំណេះដឹងជំនាញអប់រំ និងភាសា ដោយហេតុថាភាគច្រើនមិនមានការជឿទុកចិត្តលើសមត្ថភាពការងាររបស់ខ្លួនប៉ុន្មានទេ ហើយមួយចំនួនដែលចេះច្រើនភាសា ក៏មិនមានជំនឿថាខ្លួនមានសមត្ថភាពគ្រប់គ្រាន់សម្រាប់អនាគតការងារដែរ ព្រោះមកពីចំណេះខាងភាសានីមួយៗមានកម្រិតទាបឬមិនមានភាពច្បាស់លាស់។ បញ្ហាចំបងមួយទៀត គឺការខ្វះខាតនូវជំនាញដែលជាតម្រូវការទីផ្សារដោយនិស្សិត និងស្ថាប័នអប់រំភាគច្រើនផ្តោតតែទៅលើមុខជំនាញវិទ្យាសាស្ត្រសង្គម ចំណែកឯមុខជំនាញខាងផ្នែកបច្ចេកទេស វិទ្យាសាស្ត្រពិតដែលកំពុងខ្វះខាតក្នុងទីផ្សារនៅមិនទាន់មាននិស្សិតច្រើនទេដែលចាប់អារម្មណ៍សិក្សា ហើយនេះជាបញ្ហាពិបាកសម្រាប់ពួកគេទទួលបានការងារ ផ្ទុយទៅវិញវានឹងជាឱកាសសម្រាប់ពលករជំនាញបរទេសមកដណ្តើមក្នុងទីផ្សារការងារនេះ។ មួយវិញទៀត និស្សិតភាគតិចប៉ុណ្ណោះដែលមានការយល់ដឹងខ្លះៗពីអាស៊ាន ដែលនេះជាការគួរឲ្យព្រួយបារម្ភចំពោះសមត្ថភាពដែលពួកគេអាចចាប់យកឱកាសការងារបានក្នុងអនាគតទីផ្សារ។

ជាចុងក្រោយឃើញថា យុវជនភាគច្រើនយល់ថាពួកគេមានសមត្ថភាពអាចប្រកួតប្រជែងក្នុងទីផ្សារការងារបានត្រឹមកម្រិតមធ្យមប៉ុននោះ ដែលនេះសបញ្ជាក់ឲ្យឃើញថាយុវជនកម្ពុជាត្រូវតែពង្រឹងនូវគុណភាពសិក្សា សមត្ថភាពជំនាញ ចំណេះដឹង ចំណេះធ្វើ ជំនាញទន់ ផ្នែកបច្ចេកវិទ្យា និងជំនាញភាសា ពីព្រោះថា សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន២០១៥ យើងនឹងមានឱកាសស្មើគ្នា ហើយវាក៏ជាការប្រកួតប្រជែងដោយគ្មានព្រំដែននៅក្នុងទីផ្សារការងារ ។

# អនុសាសន៍

តាមរយៈលទ្ធផលនៃការស្រាវជាវ ក៏ដូចជាការអង្កេតទៅលើយុវជនជានិស្សិតមួយចំនួនក្នុងរាជធានីភ្នំពេញមក នាងខ្ញុំឃើញថា យុវជនដែលជានិស្សិត ហាក់ដូចជាមិនទាន់ត្រៀមខ្លួនរួចរាល់សម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់នៅឡើយទេ។

ដូច្នេះជាអនុសាសន៍ ដើម្បីត្រៀមខ្លួនចូលសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន២០១៥ នាពេលដ៏ខ្លីខាងមុខនេះ មិនថារដ្ឋាភិបាល និងយុវជននោះទេត្រូវតែមានវិធានការដោះស្រាយនូវអ្វីដែលជាការប្រឈមនឹងរារាំងដល់សេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេស ជាអាទិ៍៖

**កត្តារដ្ឋាភិបាល**

ទី១. ត្រូវធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ ដើម្បីឲ្យមានគុណភាព និងប្រសិទ្ធិភាពតាំងពីថ្នាក់បឋមសិក្សា រហូតដល់ឧត្តមសិក្សា។

ទី២.បង្កើនការផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយអំពី អាស៊ានតាមគ្រប់មធ្យោបាយដូចជាតាមរយៈប្រព័ន្ធផ្សាយព័ត៌មានតាមរយៈគេហទំព័រផ្លូវការរបស់រដ្ឋាភិបាលនិងតាមរយៈគ្រឹះស្ថានសិក្សានានាជាដើម។

ទី៣.ត្រូវជំរុញឲ្យស្ថាប័នពាក់ព័ន្ធបកប្រែឯកសារជាភាសាជាតិឲ្យបានច្រើនដែលអាចជួយផ្សព្វផ្សាយព័ត៌មានពីអាស៊ានដល់យុវជនខ្មែររឹតតែទូលំទូលាយថែមទៀតផង។

ទី៤.លុបបំបាត់បញ្ហាគ្មានតម្លាភាពបញ្ហាពុករលួយ ការអនុវត្តច្បាប់មិនគ្រប់ជ្រុងជ្រោយ និងកង្វះឯករាជ្យនៃប្រព័ន្ធតុលាការអាចធ្វើឲ្យវិនិយោគិនមានការរារែកមិនហ៊ានមកវិនិយោគនៅក្នុងប្រទេសកម្ពុជា ហើយអាចបង្វែរទៅកាន់ប្រទេសអាស៊ានផ្សេងទៀតដែលគេមើលឃើញថាមានហានិភ័យទាបជាង ដែលធ្វើឱ្យយុវជនកម្ពុជាបាត់បង់ឱកាស។

ទី៥. រៀបចំអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ថ្នល់ ស្ពាន ផ្លូវគោក ផ្លូវដែកផ្លូវទឹក ផ្លូវអាកាស ដែលជាចំណុចសំខាន់ក្នុងការទាក់ទាញអ្នកវិនិយោគ ដែលធ្វើឲ្យយុវជននឹងទទួលបានការងារធ្វើ។

**កត្តារដ្ឋាយុវជន**

ទី១.ការបង្កើនចំណេះដឹងភាសាអង់គ្លេសគឺជារឿងចាំបាច់សម្រាប់ពលរដ្ឋខ្មែរជាទូទៅជាពិសេសសម្រាប់និស្សិតបញ្ញវន្តទាំងឡាយពីព្រោះភាសាបរទេសគឺជាយានដ៏សំខាន់មួយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជា។[52]

[52] ស៊ុន ចាន់ថុល, ″អាស៊ាន និងសមាហរណកម្មអាស៊ាន″(បទបង្ហាញនៅក្នុងពិធីជួបជុំយុវជននិងនិស្សិត,សាលមហោស្រពកោះពេជ្រ,១២ មិថុនា ២០១៤)។

ទី២.យុវជនត្រូវពង្រឹងសមត្ថភាពខ្លួនឯងឱ្យប្រសើរឡើង គឺសមត្ថភាពជំនាញ ទាំងជំនាញវិជ្ជាជីវៈ និងជំនាញទន់ ជំនាញភាសា និងការយល់ដឹងពីផ្នែកវិទ្យាដើម្បីប្រកួតប្រជែងជាមួយយុវជនក្នុងតំបន់។

ទី៣.យុវជនត្រូវតែនាំគ្នាចាប់អារម្មណ៍ តាមដានព័ត៌មានដើម្បីយល់ដឹងពីបច្ចុប្បន្នភាព ពីសេដ្ឋកិច្ច ទំនាក់ទំនងការទូត សង្គមវប្បធម៌ ពីបញ្ហាតំបន់និងពិភពលោកផងដែរ ថាតើមានអ្វីកំពុងកើតឡើង ហើយអ្វីដែលអាចនឹងកើតមានឡើងនាពេលខាងមុខ។

សរុបមក ដើម្បីឲ្យប្រទេសជាតិរីកចម្រើនទៅបាននៅក្នុងប្លុកសេដ្ឋកិច្ចអាស៊ាននេះ ត្រូវតែមានការចូលរួមយ៉ាងសកម្មពីសំណាក់រាជរដ្ឋាភិបាល និងការសម្រួល ការដោះស្រាយ បញ្ហានានាឲ្យមានលក្ខខ័ណ្ឌល្អប្រសើរ និងការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ជាពិសេសយុវជន ដែលជាទំពាំងស្នងឬស្សី និងជាអនាគតអ្នកដឹកនាំប្រទេសជាតិបន្តទាំងឡាយ ត្រូវមានការស្វះស្វែងក្នុងការអភិវឌ្ឍជំនាញ សមត្ថភាព និងសីលធម៌ផ្ទាល់ខ្លួន ដើម្បីកិត្តិយសនិងវឌ្ឍនភាពប្រទេសជាតិនៅថ្ងៃអនាគត។

# ឯកសារយោង

## I. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

ធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍, ១៥ ធ្នូ ២០០៨។

កិច្ចព្រមព្រៀងបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន, ០៨ សីហា ១៩៦៧។

គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា, ២៤ មិថុនា ២០១១។

យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣, កញ្ញា ២០១៣។


## II. ឯកសារស្នាដៃនិពន្ធ


បណ្ឌិត ឈុន ណារ៉េត. ២០១០. *អាស៊ាន និងសមាហរណកម្ម.* ភ្នំពេញ។

បណ្ឌិត ឈុន ណារ៉េត. ២០០៧. *ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ.* ភ្នំពេញ៖ សុខ លាភ។

វ៉ាន់ឌី កាអុន. ២០០៨. *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា*។

បណ្ឌិត ចាប សុថារិទ្ធិ. ២០០៥. *កម្ពុជាក្នុងអាស៊ានប្រាំឆ្នាំក្រោយ។*


## III. ឯកសារបរទេស


The Asean Declaration Bangkok, (1967).

Treaty of Amity and Cooperation in Southeast Asia Indonesia, (1976).


## IV. បទសម្ភាសដែលបានចេញផ្សាយ តាមវិទ្យុ និងទូរទស្សន៍


ហៃ ហ៊ុនឡេង. ២០១៥. បទសម្ភាសដោយ កង កល្យាណ. *ទូរទស្សន៍ ស៊ី ធី អិន.* ២៥ មិថុនា។

ង៉ោល គាន. ២០១៥. បទសម្ភាសដោយ កង កល្យាណ. *ទូរទស្សន៍ ស៊ី ធី អិន.* ២៥ មិថុនា។

អ៊ុង វ៉ាន់ធឿន. ២០១៤. បទសម្ភាសដោយ ទេព សុភ៉ារី. *វិទ្យុអាស៊ីសេរី.* ២១ ធ្នូ។

បណ្ឌិត សុក ស៊ីផាន់ណា. ២០១៤. ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអនុវត្តកម្ពុជា (CDRI), បទសម្ភាសដោយ ជី វីតា. *វិទ្យុអាស៊ីសេរី.* ២៨ កុម្ភៈ។


## V. ឯកសារធ្វើបទបង្ហាញ


ស៊ុន ចាន់ថុល. ២០១៥. ការត្រៀមខ្លួនសម្រាប់សមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន. បទបង្ហាញនៅក្នុងវេទិកាវិស័យឯកជនតាមបណ្តាខេត្ត, ២៣-២៤ កុម្ភៈ។

ស៊ុន ចាន់ថុល. ២០១៤. អាស៊ាន និងសមាហរណកម្មអាស៊ាន. បទបង្ហាញនៅក្នុងពិធីជួបជុំយុវជន និង និស្សិត, សាលមហោស្រពកោះពេជ្រ, ១២ មិថុនា។

ហោ ណាំហុង. ២០១៤. អាស៊ាន និងសមាហរណកម្មអាស៊ាន. បទបង្ហាញនៅក្នុងពិធីជួបជុំយុវជន និង និស្សិត, សាលមហោស្រពកោះពេជ្រ, ១២ មិថុនា។

## VI. **សារព័ត៌មានតាមគេហទំព័រនានា**


អ៊ឹម រចនា. យុវជនខ្មែរត្រូវត្រៀមខ្លួនប្រែកទីផ្សារការងារពេលអាស៊ានប្រែខ្លួនជាសហគមន៍តែមួយ. *វិទ្យុបារាំងអន្តរជាតិជាខេមរភាសា*, ០៣ មិថុនា, http://km.rfi.fr/cambodia/khmer-youth-labor-ready-interference-asean-substantially-same-community-03-06-2015 (បានចូលមើលចុងក្រោយ ០៤ មិថុនា ២០១៥)។

មុនី សិទ្ធីណា. ជំនាញភាសាអង់គ្លេសជាតម្រូវការក្នុងសមាហរណកម្មអាស៊ាន. *កាសែតខ្មែរថែមស៍*, ៧ ឧសភា ឆ្នាំ២០១៥, http://www.khmertimeskh.com/news/11120/english-skills-in-demand-as-asean-integrates (បានចូលមើលចុងក្រោយ ០៤ មិថុនា ២០១៥)។

ឃួន ធារ៉ា. ២០១៤. ផលប្រយោជន៍ និងផលវិបាកកម្ពុជាចូលជាសមាជិកអាស៊ាន. *សម្លេងសហរដ្ឋអាមេរិក*, ០១ ឧសភា, http://khmer.voanews.com/content/fifteen-years-into-asean-cambodia-membership-challenges-remain/1904759.html (បានចូលមើលចុងក្រោយ ១៤ ឧសភា ២០១៥)។

ប៉ែន បូណា. ២០១៤. អាស៊ានអវត្តមានពីក្នុងអារម្មណ៍ពលរដ្ឋខ្មែរ. *វិទ្យុបារាំងអន្តរជាតិជាខេមរភាសា*, ១៦ តុលា, http://km.rfi.fr/cambodia-asian-is-absent-from-most-of-khmer-people-feel-16-10-2014/ (បានចូលមើលចុងក្រោយ ១៥ ឧសភា ២០១៥)។

ប៉ែន បូណា. ២០១៤. កម្ពុជាខ្វះធនធានមនុស្សដ៏ពូកែ. *វិទ្យុបារាំងអន្តរជាតិជាខេមរភាសា*, ២០ វិច្ឆិកា, http://km.rfi.fr/ cambodia-lack-of-best-human-resource/ (បានចូលមើលចុងក្រោយ ១៥ ឧសភា ២០១៥)។

ទេព អឺវិសាល. ២០១៤. តើអ្វីជាសមាហរណកម្មអាស៊ាន២០១៥. *ថ្មីថ្មី*, ២០ តុលា, http://www.thmey thmey.com.kh.html (បានចូលមើលចុងក្រោយ ១៣ ឧសភា ២០១៥)។

Joseph Matthews. 2015. Youth Fears About Integration at Year's End [យុវជនភ័យខ្លាចសមាហរណកម្មអាស៊ាននៅដំណាច់ឆ្នាំ]. *Khmer Times*, ០២ មេសា, http://www.khmertimeskh.com/news/10196/youth-fears-about-asean-integration-at-year---send/ (បានចូលមើលចុងក្រោយ ៣០ ឧសភា ២០១៥)។

Chea Vannak . 2015. Khmer Youth Worry About Approaching Asean Integration [យុវជនខ្មែរព្រួយបារម្ភពីការខិតជិតមកដល់សមាហរណកម្មអាស៊ាន]. *Khmer Times*, ២៩ មិនា, http://www.khmertimeskh.com/news/10095/khmer-youth-worry-about-approaching-asean-integration/ (បានចូលមើលចុងក្រោយ ៣០ ឧសភា ២០១៥)។

William E. Todd. 2015. ASEAN Integration: An Opportunity for Business in Cambodia [សមាហរណកម្មអាស៊ាន៖ ឱកាសមួយសម្រាប់អាជីវកម្មនៅកម្ពុជា]. *The Cambodia Herald*, ១១ មករា, http://www.thecambodiaherald.com/opinion/asean-integration:-an-opportunity-for-business-in-cambodia-1265(បានចូលមើលចុងក្រោយ ០១ មិថុនា ២០១៥)។

Bretton Sciaroni. 2015. Cambodia Students need a global education [និស្សិតកម្ពុជាត្រូវការចំណេះដឹងសកល]. *Phnom Penh Post*, ២៥ មេសា, http://www.phnompenhpost.com/analysis-and-op-ed/cambodian-students-need-global-education (បានចូលមើលចុងក្រោយ ០១ មិថុនា ២០១៥)។

Sen David. 2012. Professional Skills needed for ASEAN 2015 [ជំនាញវិជ្ជាជីវៈជាតម្រូវការសមាហរណកម្មអាស៊ាន២០១៥]. *Phnom Penh Post*, ២២ សីហា, http://www.phnompenhpost.com/analysis-and-op-ed/cambodian-students-need-global-education (បានចូលមើលចុងក្រោយ ០១ មិថុនា ២០១២)។

Hang Chuon Naron និង Anne Lemaistre. 2014. With A High Literacy Rate Cambodia Can Acquire More Skills [ជាមួយអត្រាអក្ខរកម្មខ្ពស់ កម្ពុជាអាចទទួលបានជំនាញបន្ថែម]. *The Cambodia Daily*, ១១ កញ្ញា, https://www.cambodiadaily.com/opinion/with-a-high-literacy-rate-cambodians-can-acquire-more-skills-67889/ (បានចូលមើលចុងក្រោយ ០១ មិថុនា ២០១៥)។

Denise Hruby. 2014. Official Says Cambodia Not Ready for ASEAN Free Trade [មន្ត្រីនិយាយថា កម្ពុជាមិនទាន់រៀបចំខ្លួនសម្រាប់ពាណិជ្ជកម្មសេរីអាស៊ាន]. *The Cambodia Daily*, ២៨ មិនា, https://www.cambodiadaily.com/archives/official-says-cambodia-not-ready-for-asean-free-trade-55203/ (បានចូលមើលចុងក្រោយ ០១ មិថុនា ឆ្នាំ២០១៥)។

Sok Khemara. 2015. Youth Need More Skills To Compete in Integrated ASEAN, Expert Says [យុវជនត្រូវការជំនាញបន្ថែមទៀតដើម្បីប្រកួតក្នុងសមាហរណកម្មអាស៊ាន, អ្នកជំនាញនិយាយ]. *VOA Khmer*, ០៧ កុម្ភៈ, http://m.voacambodia.com/a/youth-need-more-skills-to-compete-in-integrated-asean-expert-says/2632198.html (បានចូលមើលចុងក្រោយ ៣០ ឧសភា ២០១៥)។

Say Mony. 2012. Cambodian Youth Ill-Equipped for ASEAN Integration: Advocates [ការតស៊ូមតិ៖ ធនធានយុវជនកម្ពុជាមិនទាន់មានគុណភាពសម្រាប់សមាហរណកម្មអាស៊ាន]. *VOA Khmer*, ១៣ មករា, http://www.voacambodia.com/content/cambodian-youth-ill-equipped-for-asean-integration-advocates-137295743/1359540.html (បានចូលមើលចុងក្រោយ ០១ មិថុនា ២០១៥)។